**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


## របាយការណ៍បញ្ចប់ការសិក្សា

# តួនាទីក្រឡាបញ្ជីសវនាការក្នុងរឿងព្រហ្មទណ្ឌ

មណ្ឌលចុះកម្មសិក្សា ៖ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

កម្មសិក្សា ៖ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦


តាក់តែងឡើងដោយ

និស្សិតឈ្មោះ: **យី សុភាព**

**ក. អ៊ុយ សុខមុី**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ប៊ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **យី សុភាព** និងនាងខ្ញុំឈ្មោះ **អ៊ុយ សុខមុី** ជានិស្សិតឆ្នាំទី៤ ផ្នែកនីតិសាស្រ្តនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើរបាយការណ៍បញ្ចប់ការសិក្សាផ្នែកព្រហ្មទណ្ឌលើប្រធានបទស្ដីពី **"តួនាទីក្រឡាបញ្ជីសវនាការក្នុងរឿងព្រហ្មទណ្ឌ"** ។

## សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ

លោកអ្នកមានគុណទាំងពីរដែលបានផ្ដល់កំណើតចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ និងបានជួយជ្រោមជ្រែងគ្រប់បែបយ៉ាងដល់រូបខ្ញុំបាទ និងនាងខ្ញុំ ដោយលោកបានចំណាយទាំងថវិកា ទាំងស្មារតី ទាំងពេលវេលា និងសម្ភារៈផ្ដល់ដល់រូបកូនតាំងពីនៅតូចរហូតដល់ថ្ងៃនេះ ដែលធ្វើឲ្យខ្ញុំបាទ និងនាងខ្ញុំ មានលទ្ធភាពអាចចូលរៀនរហូតបានបញ្ចប់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ។

**ឯកឧត្តមសកលវិទ្យាធិការ និងឯកឧត្តមសកលវិទ្យាធិការរង** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោក-អ្នកស្រីប្រធាន និង អនុប្រធានការិយាល័យសិក្សា លោកគ្រូ-អ្នកគ្រូបន្ទុកថ្នាក់ និងលោកគ្រូ-អ្នកគ្រូបណ្ដុះបណ្ដាល ព្រមទាំងមន្ត្រីដែលបានបម្រើការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្តក្នុងការអប់រំ និងបណ្ដុះបណ្ដាល យើងខ្ញុំឲ្យក្លាយជានិស្សិតម្នាក់ដែលសេចក្ដីថ្លៃថ្នូរ ប្រកបដោយចំណេះដឹង និងសមត្ថភាពពេញលេញ ដើម្បីជាទុនដ៏មានប្រសិទ្ធិភាពក្នុងការបម្រើនូវវិស័យយុត្តិធម៌ ទៅតាមវិជ្ជាជីវៈនាពេលខាងមុខនេះ ។

**លោកប្រធាន** សាលាដំបូងរាជធានីភ្នំពេញ និង **ឯកឧត្តមព្រះរាជអាជ្ញា** នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានអនុញ្ញាតឲ្យពួកយើងខ្ញុំបានចុះកម្មសិក្សានៅសាលាដំបូងរាជធានីភ្នំពេញ និងលោក-លោកស្រីចៅក្រម លោក-លោកស្រីព្រះរាជអាជ្ញារង និងលោក-លោកស្រីក្រឡាបញ្ជី ដែលបានបម្រើការងារនៅសាលាដំបូងរាជធានីភ្នំពេញ ដែលលោកទាំងអស់បានចំណាយនូវកម្លាំងកាយកម្លាំងចិត្ត ទាំងពេលវេលា ព្រមទាំងបានផ្ដល់ នូវចំណេះដឹង និងចែករំលែកនូវបទពិសោធន៍ល្អៗ ទាក់ទិននឹងការអនុវត្តជាក់ស្ដែងការងារក្នុងការបំពេញវិជ្ជាជីវៈជាក្រឡាបញ្ជីរួមទាំងផ្ដល់នូវឯកសារមួយចំនួនទៀតដែលធ្វើឲ្យរបាយការណ៍មួយនេះមានលក្ខណៈពេញលេញ និងល្អប្រសើរ។

ជាពិសេសលោកគ្រូ **ជួន ម៉ុនធី** ជាគ្រូដឹកនាំក្នុងការសរសេរនូវរបាយការណ៍នេះផ្ទាល់ ដោយលោកបានលះបង់អស់នូវកម្លាំងកាយ កម្លាំងចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃរបស់ខ្លួនខិតខំប្រឹងប្រែងណែនាំ កែសម្រួល ទាំងអត្ថន័យ ទាំងអត្ថរស ពិនិត្យពាក្យពេជន៍អក្ខរាវិរុទ្ធ ឃ្លោងឃ្លា នៅក្នុងរបាយការណ៍មួយនេះដែលធ្វើឲ្យមានភាពល្អប្រសើរ។

ចុងបញ្ចប់យើងខ្ញុំទាំងពីររូប សូមប្រសិទ្ធពរជ័យជូនដល់លោកអ្នកដែលមានគុណទាំងអស់ដូចដែលបានរាប់ខាងលើ សូមឲ្យលោកបានជួបតែសេចក្ដីសុខ និងពុទ្ធពរជ័យទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរយៈពេល០៣ឆ្នាំ ០៦ខែរួចមក បានធ្វើឲ្យយើងខ្ញុំមានមោទនភាពជាពន់ពេក ព្រោះដោយសារយើងទាំងពីររូបមិននឹកស្មានថាបានទទួលនូវលទ្ធផលល្អក្នុងឆ្នាំទី៣ និងបានជាប់ចំណាត់ថ្នាក់ក្នុងការសរសេររបាយការណ៍បញ្ចប់នូវការសិក្សានោះទេ ។ ក្រោយពីយើងខ្ញុំទាំងពីរនាក់បានចុះកម្មសិក្សានៅសាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញកន្លងមក បានធ្វើឲ្យខ្ញុំចាប់អារម្មណ៍នូវតួនាទីរបស់ក្រឡាបញ្ជីយ៉ាងខ្លាំង ហើយយើងទាំងពីរនាក់ក៏បានសម្រេចចិត្តតាក់តែងនូវរបាយការណ៍មួយដែលទាក់ទងនឹងក្រឡាបញ្ជី ព្រោះខ្ញុំសង្កេតឃើញថាក្រឡាបញ្ជីមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមផ្ដល់នូវយុត្តិធម៌មួយផ្នែកជូនសង្គម និងផ្ដល់នូវសេវាសាធារណៈជូនដល់ប្រពលរដ្ឋផងដែរ ។ ទាំងចៅក្រម ទាំងព្រះរាជអាជ្ញា និងក្រឡាបញ្ជី សុទ្ធតែមានឆន្ទៈក្នុងការបំពេញបេសកកម្មផ្ដល់នូវយុត្តិធម៌នៅក្នុងស្ថាប័នតុលាការតែមួយដូចគ្នា ។ នៅក្នុងការបំពេញការងារក្រឡាបញ្ជីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាទុកនូវសំណុំរឿង ការកត់ត្រានូវកំណត់ហេតុនៅគ្រប់ពេលវេលាទាំងក្នុងរឿងក្ដីរដ្ឋប្បវេណី និងក្នុងរឿងព្រហ្មទណ្ឌ ។ ជាពិសេស នៅក្នុងរឿងព្រហ្មទណ្ឌក្រឡាបញ្ជីបានចូលរួមគ្រប់កិច្ចនីតិវិធីទាំងអស់ ទាំងនៅដំណាក់កាលអយ្យការ ទាំងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ក៏ដូចជាការចាត់ចែងការងារខាងផ្នែកបច្ចេកទេស និងផ្នែករដ្ឋបាលក្នុងយុត្តាធិការនេះផងដែរ ។ ចំណែកក្នុងរឿងក្ដីរដ្ឋប្បវេណីវិញ ក្រឡាបញ្ជីក៏បាន ចូលរួមគ្រប់នីតិវិធីដូចជាការទទួលពាក្យបណ្ដឹង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ រួមជាការផ្ទុកផ្ដាក់ចុះបញ្ជីផងដែរ ។

ក្រឡាបញ្ជីដើរតួនាទីយ៉ាងសំខាន់នៅគ្រប់ ដំណាក់កាលនីមួយៗ ប៉ុន្តែខ្ញុំចាប់អារម្មណ៍តួនាទីក្រឡាបញ្ជីនៅក្នុងពេលសវនាការជាងគេ ព្រោះក្រឡាបញ្ជីសវនាការបានដើរតួនាទីយ៉ាងសំខាន់តាំងពីពេលសំណុំរឿងទៅដល់យុត្តាធិការជំនុំជម្រះ រហូតដល់ការសម្រេចសេចក្ដីចេញសាលក្រមជាស្ថាពរ ។ ហេតុនេះហើយទើបទាមទារឲ្យក្រឡាបញ្ជី ត្រូវមានភាពប៉ិនប្រសប់ និងមានភាពរហ័សរហួន ដើម្បីធ្វើការកត់ត្រានូវកំណត់ហេតុឲ្យបានល្អ និង បានត្រឹមត្រូវតាមហេតុការណ៍ដែលបានកើតឡើង និងឲ្យបានទាន់ពេលវេលា ។

ការលើកឡើងនូវប្រធានបទសម្រាប់ការសិក្សាស្រាវជ្រាវស្ដីពី **"តួនាទីក្រឡាបញ្ជីសវនាការក្នុងរឿងព្រហ្មទណ្ឌ"** មួយនេះក្នុងគោលដៅចង់សិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅនៅក្នុងដំណើរការសវនាការ និងបច្ចេកទេសនៅក្នុងការសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញទុកជាមេរៀនមួយសម្រាប់យើងខ្ញុំធ្វើជាបទពិសោធការងារផ្នែកក្រឡាបញ្ជី និងជាគន្លឹះមួយសម្រាប់សិស្សជំនាន់ក្រោយៗឲ្យបានយល់អំពីតួនាទីរបស់ក្រឡាបញ្ជី នៅពេលសវនាការដែលបានកំណត់ទាំងនៅក្នុងច្បាប់ព្រមទាំងការអនុវត្តជាក់ស្ដែងដែលមាននៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងនៅតាមបណ្ដាលខេត្តផ្សេងៗទៀត។

# បញ្ជីរាយឧសម្ព័ន្ធ

| ល.រ | ឈ្មោះឧបស័ន្ធ |
|---|---|
| ០១ | ដីកាបញ្ជូនរឿងទៅជំនុំជម្រះ |
| ០២ | ដីកាលើកលែងការចោទប្រកាន់ |
| ០៣ | ដីកាសម្រេចប្រគល់វត្ថុចាប់យក |
| ០៤ | ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ |
| ០៥ | កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម |
| ០៦ | បញ្ជីរាយមុខលិខិត |
| ០៧ | តារាងកាលវិភាគសម្រាប់សវនាការ |
| ០៨ | លិខិតស្នើសុំតំណាងអយ្យការចូលរួមសវនាការ |
| ០៩ | ដីកាបង្គាប់ឲ្យនាំជនជាប់ចោទចូលសវនាការ |
| ១០ | ដីកាកោះហៅ |
| ១១ | ដីកាកោះហៅឲ្យចូលសវនាការ |
| ១២ | លិខិតអញ្ជើញ |
| ១៣ | បញ្ជីឈ្មោះមន្ត្រីទទួលបន្ទុកក្នុងការបញ្ជូន |
| ១៤ | បង្កាន់ដៃប្រៃសនីយ៍ |
| ១៥ | បទបញ្ជាផ្ទៃក្នុងសវនាការ |
| ១៦ | ដីកាបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួន |
| ១៧ | សម្រង់សាលក្រម |
| ១៨ | សាលក្រម |
| ១៩ | លិខិតជូនដំណឹងស្តីពីសាលក្រមកំបាំងមុខ |
| ២០ | ពាក្យបណ្តឹងឧទ្ធរណ៍ |
| ២១ | សេចក្តីចម្លងឧទ្ធរណ៍ |

# មាតិកា


សេចក្តីផ្តើម ............................................................ ០១

ជំពូកទី១ ៖ តួនាទីក្រឡាបញ្ជីនៅមុនពេលសវនាការ ............................. ០៣

ផ្នែកទី១ សញ្ញាណទូទៅនៃក្រឡាបញ្ជី ............................................ ០៣

កថាខណ្ឌទី១ និយមន័យក្រឡាបញ្ជី ............................................. ០៣

កថាខណ្ឌទី២ ប្រវត្តិនៃការកកើតក្រឡាបញ្ជី ..................................... ០៤

កថាខណ្ឌទី៣ គោលបំណងនៃការបង្កើតឲ្យមានក្រឡាបញ្ជី ........................ ០៤

ផ្នែកទី១ របៀបប្តឹងទៅតុលាការដើម្បីធ្វើការជំនុំជម្រះ ............................ ០៥

កថាខណ្ឌ ១ ការប្តឹងទៅតុលាការរបស់យុត្តាធិការស៊ើបសួរ ......................... ០៥

ក. ការប្តឹងរបស់ចៅក្រមស៊ើបសួរ ................................................ ០៦

ខ. សភាស៊ើបសួរ ............................................................... ០៧

កថាខណ្ឌ២ ប្រភពមកពីស្ថាប័នអយ្យការ .......................................... ០៨

ក. ដីកាកោះទៅជម្រះផ្ទាល់ .................................................... ០៨

ខ. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម ............................................... ០៩

ផ្នែកទី២ តួនាទីក្រឡាបញ្ជីក្នុងការទទួល និងថែរក្សាសំណុំរឿង ..................... ១១

កថាខណ្ឌទី១ តួនាទីក្នុងការទទួលសំណុំរឿង ...................................... ១១

ក. ការពិនិត្យផ្ទៀងផ្ទាត់ ឯកសារនៅក្នុងសំណុំរឿង ................................ ១១

ខ. តួនាទីការរក្សាទុកសំណុំរឿង ................................................ ១២

កថាខណ្ឌ២ តួនាទីក្នុងការព្រាងដីកា និងលិខិតផ្សេងៗ ........................... ១៣

ក. ការត្រួតពិនិត្យកាលបរិច្ឆេទនៃការជំនុំជម្រះ .................................. ១៣

ខ.ប្រភេទនៃដីកា និងលិខិតដែលត្រូវព្រាង ....................................... ១៤

គ.សមត្ថកិច្ចក្នុងការតែងនិពន្ធ និងទម្រង់បែបបទ ................................. ១៤

កថាខណ្ឌទី ៣ ការបញ្ជូនដីកាកោះហៅឲ្យចូលសវនាការ ........................... ១៥

ក.ស្ថាប័នអនុវត្តកិច្ចការបញ្ជូន ................................................. ១៦

ខ.នីតិវិធីនៃការបញ្ជូន ........................................................ ១៩

ជំពូកទី២៖ តួនាទីក្រឡាបញ្ជីក្នុងពេលសវនាការ .................................. ២១

ផ្នែកទី១ តួនាទីក្រឡាបញ្ជីមុនពេលប្រកាសបើកសវនាការ .......................... ២១

កថាខណ្ឌទី១ ការរៀបចំបន្ទប់នៃសាលសវនាការ.............................................................២១
ក.ការរៀបចំទុកដាក់វត្ថុតាង និងគ្រឿងក្រចកសេះសម្រាប់ជនជាប់ចោទ .............២២
ខ.រៀបចំបន្ទប់សម្រាប់ជនជាប់ចោទ និងសាក្សី..........................................................២២
កថាខណ្ឌទី២ ការរៀបចំការងារផ្នែកសន្តិសុខ ..........................................................២៣
ក.ការពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកចូលរួម ..........................................២៤
ខ.ត្រៀមរៀបចំលិខិតរដ្ឋបាលស្នើសុំកម្លាំងការពារ...............................................២៤
គ.ការដឹកនាំធ្វើសម្បថ ......................................................................................................២៥
ផ្នែកទី២ តួនាទីក្រឡាបញ្ជីក្នុងអំឡុងពេលប្រកាសបើកសវនាការ..........................២៦
កថាខណ្ឌទី១ ពេលដំណើរការនីតិវិធីសវនាការ .....................................................២៦
ក. ការកត់ត្រានូវដំណើរការសវនាការ .........................................................................២៦
ខ.ការអាននូវកំណត់ហេតុសវនាការ ............................................................................២៧
កថាខណ្ឌទី២ ការប្រកាសសេចក្តីសម្រេច.................................................................២៧
ក.ការថយទៅពិភាក្សា..........................................................................................................២៨
ខ.ការប្រកាសសាលក្រម ......................................................................................................២៨
ជំពូកទី៣ តួនាទីក្រឡាបញ្ជីក្រោយដំណាក់កាលសវនាការ.........................................២៩
ផ្នែកទី១ ការព្រាងឯកសារដែលទាក់ទងសាលក្រម និងការជូនដំណឹង............២៩
កថាខណ្ឌទី១ ប្រភេទឯកសារដែលត្រូវព្រាង .............................................................២៩
ក.ដីកាបង្គាប់ចាប់ និងឃុំខ្លួនតាមសាលក្រម ..............................................................២៩
ខ.សម្រង់សាលក្រម ..............................................................................................................៣០
គ.សាលក្រម.............................................................................................................................៣១
កថាខណ្ឌទី២ ការជូនដំណឹងអំពីសាលក្រម .............................................................៣២
ក. សាលក្រមចំពោះមុខ.......................................................................................................៣២
ខ. សាលក្រមចាត់ទុកចំពោះមុខ .......................................................................................៣៣
គ. សាលក្រមកំបាំងមុខ ......................................................................................................៣៣
ផ្នែកទី២ តួនាទីក្នុងការទទួលបណ្តឹងឧបាស្រ័យ ..........................................................៣៤
កថាខណ្ឌទី១ ប្រភេទនៃបណ្តឹងឧបាស្រ័យ.....................................................................៣៤
ក.បណ្តឹងឧទ្ធរណ៍ ......................................................................................................................៣៤

ខ.បណ្តឹងឧទ្ធរណ៍ ........ ៣៥
កថាខណ្ឌទី២ អនុភាពនៃបណ្តឹងឧបាស្រ័យ ........ ៣៦
ក. អានុភាពនៃបណ្តឹងទាស់ ........ ៣៦
ខ.អានុភាពនៃបណ្តឹងឧទ្ធរណ៍ ........ ៣៧
កថាខណ្ឌទី៣ ការបញ្ជូនបណ្តឹងឧទ្ធរណ៍ ........ ៣៧
**សេចក្តីសន្និដ្ឋាន** ........ ៣៩
**អនុសាសន៍** ........ ៤០
**បញ្ជីរាយឧសម្ព័ន្ធ**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសដែលធ្លាប់បានឆ្លងកាត់នូវការផ្លាស់ប្តូរនិន្នាការនយោបាយជាច្រើនលើកច្រើនសារដែលធ្វើឲ្យមានការបាត់បង់នូវរចនាសម្ព័ន្ធ និងយន្តការនៃការគ្រប់គ្រងរដ្ឋស្ទើរគ្រប់វិស័យជាពិសេសប្រព័ន្ធច្បាប់តែម្តង ។ ប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងរដ្ឋជាកត្តាមួយចាំបាច់ត្រូវតែបង្កើត ឬ ត្រូវធ្វើវិសោធនកម្មដើម្បីធ្វើយ៉ាងណាឲ្យស្របទៅតាមបរិបទសង្គម ។ នៅក្នុងនោះបញ្ហាសន្តិសុខសណ្តាប់ ធ្នាប់ជាកត្តាមួយដ៏សំខាន់ដែលរាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់ហើយបានធ្វើការបង្កើតនូវច្បាប់ជាច្រើនដែលក្នុងនោះរួមមាន៖ រដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ការងារ ច្បាប់ពាណិជ្ជកម្ម .ល. ។ ការបង្កើតច្បាប់នេះគឺដើម្បីកំណត់នូវវិធានគតិយុត្តនានាក្នុងការប្រតិបត្តិការងារស្របតាមស្ថានភាព និងជីវភាពក្នុងសង្គមជាក់ស្តែង។

ច្បាប់នីមួយៗដែលបង្កើតឡើងសុទ្ធសឹងតែមានបំណងច្បាស់លាស់ជារួម និងដោយឡែកដែលស្តែងចេញពីឆន្ទៈដោយសេរីនៃសមាជិកសភាដែលជាតំណាងឲ្យប្រជាពលរដ្ឋ ។ ក្នុងនោះក្រមនីតិវិធីព្រហ្មទណ្ឌដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧ ជាអត្ថបទច្បាប់ទំនើបមួយដែលបានកំណត់អំពីការចោទប្រកាន់ ការស្រាវជ្រាវបទល្មើស ការពិនិត្យភស្តុតាង ការកំណត់អំពីសមត្ថកិច្ចនិងតួនាទីរបស់អ្នកអនុវត្តច្បាប់ ដូចជាតួនាទីរបស់ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី មន្ត្រីនគរបាលយុត្តិធម៌ និងបុគ្គលដទៃទៀតដែលជាភាគីពាក់ព័ន្ធក្នុងសំណុំរឿងជាដើម ។

នៅក្នុងដំណើរការនីតិវិធីបណ្តឹងនីមួយៗយើងសង្កេតឃើញថាការងាររបស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី នគរបាលយុត្តិធម៌ គឺមានតួនាទីយ៉ាងសំខាន់រៀងៗខ្លួន ក្នុងនោះក្រឡាបញ្ជីក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរនៅក្នុងរឿងព្រហ្មទណ្ឌ ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នូវតួនាទីក្រឡាបញ្ជីនៅគ្រប់ដំណាក់កាលនីមួយៗដែលក្នុងនោះមានដូចជា៖ ដំណាក់កាលអយ្យការ ដំណាក់កាលយុត្តាធិការស៊ើបសួរ និងជាពិសេសនោះគឺនៅដំណាក់កាលសវនាការតែម្តង ។ នៅក្នុងដំណាក់កាលអយ្យការក្រមនីតិវិធីព្រហ្មទណ្ឌ ហាក់ដូចជាមិនបានកំណត់នូវតួនាទីក្រឡាបញ្ជីជាក់លាក់ ដូចដែលបានកំណត់នៅក្នុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការនោះទេ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏នៅក្នុងដំណាក់កាលអយ្យការនៅតែមានវត្តមានចូលរួមរបស់ក្រឡាបញ្ជីផងដែរ ទោះបីជាក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនបានបញ្ជាក់អំពីភាពចាំបាច់នៃវត្តមានរបស់ក្រឡាបញ្ជីនៅក្នុងដំណាក់កាលនោះក៏ដោយ។ ផ្ទុយទៅវិញនៅក្នុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ច្បាប់បែរជាបានកំណត់នូវតួនាទីក្រឡាបញ្ជីយ៉ាងច្បាស់លាស់ទៅ

វិញដូចជាមាត្រា ១២៨ ស្ដីពីជំនួយរបស់ក្រឡាបញ្ជី មាត្រា ១២៩ ការរក្សាសំណុំរឿង ការធ្វើកំណត់ហេតុ រួមទាំងមាត្រាពាក់ព័ន្ធផ្សេងទៀត ។

ក្រោយពីបានស្វែងយល់ នឹងស្រាវជ្រាវអំពីតួនាទីក្រឡាបញ្ជីនៅសាលាដំបូងរួចមកបានធ្វើឲ្យយើងខ្ញុំយល់ថាក្រឡាបញ្ជីមានគឺមានតួនាទីយ៉ាងសំខាន់ ។ តែដោយសារតែពេលវេលាក្នុងការសិក្សាស្រាវជ្រាវនិងការតាក់តែងនូវរបាយការណ៍មួយនេះមានរយៈពេលខ្លីត្រឹមតែ ៥ ខែ ប៉ុណ្ណោះសម្រាប់ធ្វើការតាក់តែងបញ្ចប់របាយការណ៍មួយនេះ ដូច្នេះហើយយើងខ្ញុំបានសម្រេចចិត្តធ្វើការជ្រើសរើសយកប្រធានបទត្រឹមតែ **តួនាទីក្រឡាបញ្ជីក្នុងពេលសវនាការ** សម្រាប់លើកយកមកចងក្រងតាក់តែងតែប៉ុណ្ណោះ ។ ជាមួយគ្នានេះដែរយើងខ្ញុំនឹងលើកឡើងលម្អិតនូវសកម្មភាពរបស់ក្រឡាបញ្ជីព្រមទាំងចំណុចសំខាន់ៗនៃការប្រព្រឹត្តទៅរបស់ក្រឡាបញ្ជីដែលមាននៅក្នុងវិស័យយុត្តាធិការជំនុំជម្រះក្នុងរឿងព្រហ្មទណ្ឌដែលទាក់ទងនឹងប្រធានបទមួយនេះ។

ចំពោះបញ្ហាដែលបានចោទសួរឡើងទាក់ទងនឹងប្រធានបទ ដែលត្រូវយកមកពិភាក្សានៅពេលនេះ តើក្រឡាបញ្ជីសវនាការនៅក្នុងរឿងព្រហ្មទណ្ឌមានសិទ្ធិ និងតួនាទីភារកិច្ចធ្វើអ្វីខ្លះ ? តើនៅមុនពេលសវនាការ ក្នុងពេលសវនាការ និងក្រោយពេលសវនាការក្រឡាបញ្ជីត្រូវបំពេញយ៉ាងដូចម្ដេច ? ចុះប្រសិនបើករណីមួយចំនួនច្បាប់មិនបានចែង តើក្រឡាបញ្ជីសវនាការអាចធ្វើបានឬមួយយ៉ាងណា ?

នៅក្នុងប្រធានបទនៃរបាយការណ៍មួយនេះខ្ញុំសូមកម្រិតនូវការបកស្រាយ ត្រឹមតែជំនាញបច្ចេកទេស និងការអនុវត្តជាក់ស្ដែងតែប៉ុណ្ណោះ គឺមិនធ្វើការបកស្រាយវិភាគពិចារណាគួបផ្សំនឹងបញ្ហានយោបាយ និងជ្រៀតជ្រែងក្នុងបញ្ហាថវិការបស់តុលាការឡើយ ។ ដូច្នេះហើយដោយឈរលើការបកស្រាយដោយផ្អែកតែក្នុងបច្ចេកទេសសុទ្ធសាធ របាយការណ៍មួយនេះត្រូវបានធ្វើការបែងចែកតួនាទីក្រឡាបញ្ជីជាបីជំពូកធំៗគឺ

**ជំពូកទី១ ស្ដីអំពីតួនាទីក្រឡាបញ្ជីមុនពេលសវនាការ** ដែលចាប់ផ្ដើមតាំងពីសំណុំរឿងបានមកដល់យុត្តាធិការជំនុំជម្រះរហូតដល់មុនពេលបើកសវនាការ ។

**ជំពូកទី២ ស្ដីពីតួនាទីក្រឡាបញ្ជីនៅពេលសវនាការ** ដែលចាប់ផ្ដើមពីដល់ការបរិច្ឆេទជំនុំជម្រះរហូតដល់ការប្រកាសសាលក្រម ។

**ជំពូកទី៣ ស្ដីពីតួនាទីក្រឡាបញ្ជីក្រោយពេលសវនាការ** គឺគិតចាប់ពីការប្រកាសសេចក្ដីសម្រេចបានបញ្ចប់រហូតដល់ការចូលជាស្ថាពរនៃសាលក្រម ។

# ជំពូកទី១
# តួនាទីក្រឡាបញ្ជីនៅពេលទទួលសំណុំរឿង

ក្រឡាបញ្ជីមានតួនាទីយ៉ាងច្រើននៅមុនពេលសវនាការ បើទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌហាក់ដូចជាពុំបាន កំណត់អំពីតួនាទីនេះជាក់លាក់យ៉ាងណាក៏ដោយ ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងនៅតាមស្ថាប័នតុលាការនីមួយៗ ក្រឡាបញ្ជីមានតួនាទីភារកិច្ចយ៉ាងច្រើន នៅមុនពេលសវនាការ។

នៅពេលសំណុំរឿងបានបញ្ជូនមកដល់បន្ទប់របស់ចៅក្រមនីមួយៗរួចហើយ ក្រឡាបញ្ជីមានតួនាទីទទួលនូវសំណុំរឿងទាំងនោះ ។ ប៉ុន្តែមុននឹងឈានទៅដល់ការទទួលនូវសំណុំរឿងក្រឡាបញ្ជីគប្បីយល់ឲ្យច្បាស់មុនសិនថាអ្វីជាក្រឡាបញ្ជី បន្ទាប់មកយើងត្រូវយល់ដឹងពីប្រភពដើមនៃសំណុំរឿងថាសំណុំរឿងណាខ្លះដែលត្រូវទទួល ហើយដើម្បីងាយស្រួលក្នុងការកំណត់កាលបរិច្ឆេទសវនាការ និងការជូនដំណឹងអំពីកាលបរិច្ឆេទសវនាការ ។

## ផ្នែកទី១ សញ្ញាណទូទៅនៃក្រឡាបញ្ជី

### កថាខណ្ឌទី១ និយមន័យក្រឡាបញ្ជី

ពាក្យក្រឡាបញ្ជីមិនមាននិយមន័យច្បាស់លាស់ណាមួយកំណត់ឲ្យបានជាក់លាក់នោះទេ ។ ប៉ុន្តែក្រោយពីបានសិក្សារួចមកពាក្យក្រឡាបញ្ជីត្រូវបានគេផ្តល់និយមន័យផ្សេងៗគ្នា ទៅតាមវនានុក្រមរបស់សម្តេច ជួន ណាត និងតាមបទដ្ឋានគតិយុត្តច្បាប់ ។

ក្រឡាបញ្ជីត្រូវបានវនានុក្រមសម្តេច ជួន ណាត បានឲ្យនិយមន័យថា ជាអ្នកមានឋានន្តរសក្តិរបស់មន្ត្រីជាន់កណ្តាលខាងតុលាការ ជាស្មៀនសម្រាប់កាន់កាប់បញ្ជី និងសំណុំរឿងផ្សេងៗ ជាដើម។ ក្នុងន័យនេះអាចបញ្ជាក់បានថាក្រឡាបញ្ជីគឺជាអ្នកដែលមានតួនាទីជាអ្នកកត់ត្រា ។

ក្រឡាបញ្ជីជាអ្នកបច្ចេកទេសផ្នែកនីតិវិធី ដើម្បីជាជំនួយសម្រួលការងារដល់អង្គការតុលាការ និងអង្គការអយ្យការ នៅក្នុងសកម្មភាពបង្កើនប្រសិទ្ធភាព និងគុណភាពនៃសេវាយុត្តិធម៌ តាមលក្ខខណ្ឌដែលមានកំណត់ក្នុងច្បាប់ ឬបទបញ្ញាធរមាន ។ ក្រឡាបញ្ជីគឺជាមន្ត្រីនៃក្រុមតុលាការស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ហើយអាចចាត់ចែងឲ្យបំពេញការងារនៅក្រសួងយុត្តិធម៌ក៏បាន នៅតាមអង្គការតុលាការក៏បាន និងនៅតាមអង្គការអយ្យការក៏បាន។ ក្នុងករណីក្រឡាបញ្ជីបម្រើការងារនៅក្រសួងយុត្តិធម៌ ក្រឡាបញ្ជីនឹងទទួលបានប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារផ្សេងៗ ដូចក្រឡាបញ្ជីដែលបម្រើការងារនៅអង្គការតុលាការ និងអង្គការអយ្យការដែរ ។

សរុបមកមក ក្រឡាបញ្ជីជាសេនាធិការផ្ទាល់របស់អង្គការតុលាការ និងអង្គការអយ្យការ ក្នុងការជួយសម្រួលដល់ការងារផ្នែកនីតិវិធី និងការងារបច្ចេកទេស ក្នុងវិស័យតុលាការ ។

## កថាខណ្ឌទី២ ប្រវត្តិនៃការកកើតក្រឡាបញ្ជី

នាសម័យមុនសញ្ញាណក្រឡាបញ្ជីមិនទាន់មាននៅក្នុងច្បាប់នៅឡើយទេ តែបានស្តែងឡើងក្រោមរូបភាពជាមន្ត្រីតុលាការ ហៅថា "ធម្មសាស្ត្រិន" ជំនួយឲ្យចៅក្រម ដែលមានតួនាទីប្រហាក់ប្រហែលនឹងក្រឡាបញ្ជីនាពេលបច្ចុប្បន្ន ។ ធម្មសាស្ត្រិន ជាអ្នកសូត្រច្បាប់ធម្មសាស្ត្រ ហើយបុគ្គលនេះប្រហែលជាបំពេញមុខងារជាអ្នកតម្រាច្បាប់ ឬជាទីប្រឹក្សាច្បាប់ដែលចៅក្រមសួរឲ្យសូត្រមាត្រាច្បាប់ដែលទាក់ទងនឹងអង្គហេតុនៃរឿងក្តី[1] ។

តាមរយៈការធ្វើទំនើបកម្មលើវិស័យយុត្តិធម៌ប្រទេសកម្ពុជា ដោយអាណានិគមបារាំងបានធ្វើឲ្យសញ្ញាណក្រឡាបញ្ជីលេចឡើងដំបូងក្នុងបទដ្ឋានគតិយុត្តិ ។ លុះដល់សម័យបច្ចុប្បន្នប្រព័ន្ធច្បាប់ត្រូវបានគេវិសោធនកម្ម ក្រោយមកបានបង្កើតឲ្យមានច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ។ ក្នុងចន្លោះឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៨ ក៏មានការតែងតាំងក្រឡាបញ្ជីបញ្ជូនឲ្យទៅធ្វើការបណ្តុះបណ្តាល ។ បន្ទាប់មកនៅឆ្នាំ២០០៧ ប្រទេសកម្ពុជាបានវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០២ និងបានកំណត់ពីមុខងារ និងតួនាទីក្រឡាបញ្ជីយ៉ាងជាក់លាក់ ។ នៅឆ្នាំ២០០៨ ក៏មានការបង្កើតឲ្យមានការប្រឡងប្រជែងសិស្សក្រឡាបញ្ជីជំនាន់ទី១ ហើយទទួលការបណ្តុះបណ្តាលនៅសាលាភូមិន្ទក្រឡាបញ្ជី នៃរាជសភាវិជ្ជាជីវៈតុលាការលុះក្រោយមកក៏មានការជ្រើសរើសសិស្សក្រឡាបញ្ជីជាបន្តបន្ទាប់រហូតដល់បច្ចុប្បន្ន ។

## កថាខណ្ឌទី៣ គោលបំណងនៃការបង្កើតឲ្យមានក្រឡាបញ្ជី

ដោយផ្អែកតាមសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ការបង្កើតឲ្យមានក្រឡាបញ្ជីក្នុងគោលបំណងដើម្បីជាជំនួយឲ្យអង្គការតុលាការ និងអង្គការអយ្យការ ដើម្បីជួយដល់ការពន្លឿននៃនីតិវិធី សេវាកម្ម និងប្រសិទ្ធភាពក្នុងវិស័យយុត្តិធម៌[2] ព្រោះថាតុលាការនៅតាមរាជធានី-ខេត្ត តែងតែធ្វើឲ្យសំណុំរឿងមានភាពកកស្ទះដោយហេតុថាក្រឡាបញ្ជីមាននៅមានកម្រិតតិចតួចនៅឡើយ ដែលជាហេតុធ្វើឲ្យវិស័យយុត្តិធម៌មានភាពយឺតយ៉ាវ និងបានធ្វើឲ្យប្រជាពលរដ្ឋអស់ទំនុកចិត្តលើវិស័យតុលាការ ។ នៅឆ្នាំ២០១៥សាលាដំបូងរាជធានីភ្នំពេញ បានទទួលសំណុំរឿងយ៉ាងតិចបំផុត

---

[1] សៀវភៅស្តីពីអយ្យការ ប្រវត្តិនិងការប្រៀបធៀប បោះពុម្ពលើកទី១ ឆ្នាំ២០០៦ ,និពន្ធលោក គុយ នាម និងលោក ឡុង បញ្ញាវ័ន,ទំព័រទី៤០,៤១

[2] មាត្រា១ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី

ចំនួន ២៥០០រឿង ក្នុងមួយឆ្នាំ ហើយចំនួនក្រឡាបញ្ជីមានចំនួនតែ១៣០នាក់តែប៉ុណ្ណោះ[3] ។ ម្យ៉ាងទៀត ដោយសារតែក្រឡាបញ្ជីនៅមិនទាន់មានច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជីនៅឡើយ ទើបមិនបានកំណត់អំពីតួនាទីក្រឡាបញ្ជីជាក់លាក់ ។ ជាក់ស្តែងនៅឆ្នាំ២០១៦ មានការប្រជុំមួយស្តីពីការបង្កើតសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ដែលមានការចូលរួមពីសំណាក់ក្រសួងយុត្តិធម៌រួមជាមួយក្រឡាចាស់ៗដែលបម្រើការងារនៅតុលាការជាន់ខ្ពស់ក្នុងការបង្កើតនូវច្បាប់ថ្មីនេះ ។

## ផ្នែកទី១ របៀបប្តឹងទៅតុលាការដើម្បីធ្វើការជំនុំជម្រះ

ជាការពិតណាស់ តុលាការអាចធ្វើការជំនុំជម្រះរឿងក្តីណាមួយបាន អាស្រ័យដោយមានសំណុំរឿងជាមុនសិន នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីប្រភពនៃសំណុំរឿងយ៉ាងច្បាស់លាស់ដែលបានមកពីស្ថាប័នអយ្យការ និងស្ថាប័នយុត្តាធិការស៊ើបសួរដែលក្នុងនោះមានដូចជា ៖

- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា
- កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមដែលធ្វើឡើងដោយព្រះរាជអាជ្ញា

គ្រប់បុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការតាមនីតិវិធីណាមួយខាងលើនេះ មានឈ្មោះហៅថា **ជនជាប់ចោទ**[៤] ។

### កថាខណ្ឌទី១ ការប្តឹងទៅតុលាការរបស់យុត្តាធិការស៊ើបសួរ

នៅក្នុងស្ថាប័នយុត្តាធិការស៊ើបសួរ ត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌបែងចែកជាស្ថាប័នពីរសំខាន់គឺ ចៅក្រមស៊ើបសួរ និងសភាស៊ើបសួរ ។ ចៅក្រមស៊ើបសួរមានតួនាទីបើកការស៊ើបសួរចំពោះបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម ដែលស្ថាប័នអយ្យការបានបញ្ជូនមកតាមរយៈ **ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ** ដោយការស៊ើបសួរនេះ ចៅក្រមត្រូវធ្វើការស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក[៥] ។

រីឯសភាស៊ើបសួរមានតួនាទីក្នុងការពិនិត្យមើលទៅលើមោឃភាពនៃដីកា ដែលបានចេញដោយចៅក្រមស៊ើបសួរ និងធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរនៅពេលមានការប្តឹងមកពីស្ថាប័នអយ្យការ ,ជនត្រូវចោទ និងដើបណ្តឹងរដ្ឋប្បវេណី មកកាន់សភាស៊ើបសួរ[៦] ។

---

[៣] កិច្ចសម្ភាសន៍ជាមួយប្រធានលេខាធិការដ្ឋាន នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦

[៤] មាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៥] មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៦] មាត្រា២៥៧ រហូតដល់មាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### **គ.ការប្តឹងរបស់ចៅក្រមស៊ើបសួរ**

នៅពេលអយ្យការបានបញ្ជូនសំណុំរឿង និង អមដោយដីកាសន្និដ្ឋានស្ថាពរមកផងនោះចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ ។ ក្រឡាបញ្ជីដែលទទួលបន្ទុកក្នុងការចាត់ការសំណុំរឿងនោះត្រូវធ្វើការបញ្ជូនសំណុំរឿងទៅលេខាធិការដ្ឋាន ដើម្បីឲ្យលេខាធិការដ្ឋានធ្វើការចាត់ចៅក្រមណាម្នាក់ទទួលបន្ទុកក្នុងការជំនុំជម្រះ ( ចៅក្រមជំនុំជម្រះ ) ។ ដីកាដំណោះស្រាយអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់[៧] ។

១. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ

ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលអាចបញ្ជាក់ថាអំពើនេះជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនជាប់ចោទទៅមុខតុលាការជំនុំជម្រះដោយដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ [៨] ។ ដីកាសម្រេចនេះត្រូវរៀបរាប់ចំពោះអំពើដែលត្រូវចោទប្រកាន់ និង ឈ្មោះបទល្មើសតាមច្បាប់ព្រមទាំងត្រូវសរសេរនូវសំអាងហេតុផងដែរ [៩] ។ កាលណាដែលចៅក្រមស៊ើបសួរចេញដីកាបញ្ជូនទៅជំនុំជម្រះដោយគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់នោះទេ ប្រាកដណាស់ថាជនជាប់ចោទមានលទ្ធភាពច្រើនក្នុងការរួចផុតពីការទទួលខុសត្រូវចំពោះអំពើដែលពួកគេបានប្រព្រឹត្ត ។ ចៅក្រមស៊ើបសួរដែលមិនបានប្រមូលភស្តុតាងឲ្យបានគ្រប់គ្រាន់ដើម្បីបញ្ជាក់ឲ្យអស់នូវភាពសង្ស័យនោះ ផលប្រយោជន៍ទាំងអស់ត្រូវបានទៅជនជាប់ចោទដែលស្របនឹងរដ្ឋធម្មនុញ្ញបានចែងថា "វិមតិសង្ស័យត្រូវជាប្រយោជន៍ដល់ជនជាប់ចោទ"[១០] ។

២. ដីកាលើកលែងចោទប្រកាន់

ដីកាលើកលែងចោទប្រកាន់ ត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា **២៤៧** ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរឲ្យចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចតទៅ [១១] ៖

- អំពើប្រព្រឹត្តមិនមែនជាឧក្រិដ្ឋ មជ្ឈិម ឬលហុ
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់

---

[៧] មាត្រា ២៤៧ នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ
[៨] ឧបសម្ព័ន្ធទី ០១ ស្តីពីដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ
[៩] មាត្រា ២៤៧ នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ និងឧបសម្ព័ន្ធទី ០១
[១០] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[១១] ឧបសម្ព័ន្ធទី០២ ដីកាសម្រេចលើកលែងចោទប្រកាន់

- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ
- ករណីដែលបណ្តឹងអាជ្ញារលត់

នៅក្នុងករណីដែលមានការលើកលែងការចោទប្រកាន់ ដោយសារមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនស្គាល់ ឬ ក្នុងករណីដែលជនត្រូវចោទបានទទួលមរណៈភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាម ដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍សម្ភារៈមូលនីធិផលទុន ឬ ទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធ និង បទល្មើស ។ ក្នុងករណីនេះតុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រម ក្នុងសវនាការសាធារណៈដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលដែលពាក់ព័ន្ធប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការចេញសាលក្រម ឬ ផ្សាយជាសារធារណៈតាមសារពត៌មាន ឬ មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ [១២] ។

៣. ដីកាបង្គាប់ឲ្យប្រគល់វត្ថុចាប់យកឲ្យម្ចាស់ដើមវិញ

ជាទូទៅដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចសម្រេចអំពីការប្រគល់សងទៅឲ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក [១៣] ។ នៅក្នុងករណីដែលមានការស្នើសុំពីម្ចាស់ដើមវិញក្នុងដំណាក់កាលនេះ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់តាមការស្នើសុំនេះប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការស្នើសុំ បើពុំមានផលប្រយោជន៍សម្រាប់សំដែងឲ្យឃើញការពិតនោះទេ ។ ឧទាហរណ៍ "ក" បានលួចម៉ូតូរបស់ "ខ" ។ ប៉ុន្តែនៅក្នុងដំណាក់កាលអយ្យការ ជនរងគ្រោះ ឬ ដើមបណ្តឹង ពុំបានពាក្យស្នើសុំវត្ថុចាប់យកនោះទេ រហូតមកដល់ចៅក្រមស៊ើបសួរទើបដាក់ពាក្យស្នើសុំវត្ថុចាប់យក [១៤] ហេតុនេះចៅក្រមស៊ើបសួរអាចសម្រេចប្រគល់វត្ថុចាប់យកឲ្យម្ចាស់ដើមវិញតាមការស្នើសុំ [១៥] ។

**ខ. ការបញ្ជូនសំណុំរឿងពីសភាស៊ើបសួរ**

ប្រសិនបើមានការមិនពេញចិត្តចំពោះការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ តំណាងអយ្យការ ឬ ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងទៅសភាស៊ើបសួរបាន ។

នៅពេលសភាស៊ើបសួរបានទទួលបាននូវបណ្តឹងឧទ្ធរណ៍រួចហើយ ប្រសិនបើសភាស៊ើបសួរសម្រេចថាបន្តការស៊ើបសួរដោយខ្លួនឯងនោះ សភាស៊ើបសួរអាចប្រគល់ភារកិច្ចទៅសមាជិករបស់ខ្លួនណាម្នាក់ដោយប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ លើកលែងតែអំណាចដែល

---

[១២] មាត្រា២៤៧ នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ

[១៣] មាត្រា ១១៩ នៃក្រមនិតិវិធីព្រហ្មទណ្ឌ

[១៤] មាត្រា ២៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[១៥] ឧបសម្ព័ន្ធទី ០៣ ដីកាសម្រេចប្រគល់វត្ថុចាប់យក

មានចែងនៅក្នុងជំពូកទី៥ស្តីពីការបិទស៊ើបសួរ នៃមាតិកាទី១ស្តីពីចៅក្រមស៊ើបសួរក្នុងគន្លីនៃក្រម នីតិវិធីព្រហ្មទណ្ឌ មានន័យថាចៅក្រមស៊ើបសួរដែលបានទទួលនូវការប្រគល់ភារកិច្ចឲ្យស៊ើបសួរពុំអាចប្រើប្រាស់អំណាចក្នុងការបិទការស៊ើបសួរបានទេ ។

កាលណាការស៊ើបសួរហាក់ដូចជាត្រូវបានបញ្ចប់ សំណុំរឿងត្រូវបានតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។ ប្រធានសភាស៊ើបសួរត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់មើលថា តើសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបានឬទេ ប្រសិនបើសំណុំរឿងមានលក្ខណៈធួនល្មមហើយ ប្រធានសភាស៊ើបសួរត្រូវកំណត់កាលបរិច្ឆេទបើកសវនាការ ។ ប្រធានសភាស៊ើបសួរត្រូវជូនដំណឹងដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទ នៃការបើកសវនាការដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការនេះទៅដល់គូភាគី និង ដល់មេធាវី ។ ការបើកសវនាការនេះគឺសម្រេចអំពីការបិទការស៊ើបសួរចំពោះសំណុំរឿងដែលបានស៊ើបសួរនោះប៉ុណ្ណោះ [១៦] ។

សភាស៊ើបសួរបិទការស៊ើបសួរតាមសាលដីកា ដំណោះស្រាយរួចបញ្ជូនសំណុំរឿងទៅយុត្តាធិការជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ តាមរយៈសាលដីកាបញ្ជូនដែលមានចែងនៅក្នុងមាត្រា **២៩១** ចំណុច **១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## កថាខណ្ឌទី២ ការប្តឹងរបស់ស្ថាប័នអយ្យការ

នៅក្នុងស្ថាប័នអយ្យការ សំណុំរឿងត្រូវបានបញ្ជូនមកតុលាការដើម្បីជំនុំជម្រះតាមរបៀបពីរយ៉ាងគឺ៖

-តាមរយៈដីកាកោះហៅបញ្ជូនមកជំនុំជម្រះផ្ទាល់ [ក] និង

-កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម [ខ]។

### ក. ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ [១៧]

ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាលិខិតមួយដែលស្ថាប័នអយ្យការប្តឹងទៅតុលាការដើម្បីឲ្យតុលាការកំណត់កាលបរិច្ឆេទសវនាការ ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ អាចអនុវត្តចំពោះគ្រប់បទមជ្ឈិម និងបទលហុ (ដែលមិនចូលក្នុងលក្ខខណ្ឌនៃកំណត់ហេតុបង្ហាញខ្លួនភ្លាម និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ) ។ ដីកានេះត្រូវចុះនូវអត្តសញ្ញាណជនជាប់ចោទ សេចក្តីសង្ខេបអង្គហេតុ និងអត្ថបទច្បាប់ដែលបានកំណត់នឹងបង្ក្រាបបទល្មើស ការចង្អុលបង្ហាញប្រាប់តុលាការដែលទទួលបណ្តឹង ។

---

[១៦] មាត្រា ២៨២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[១៧] ឧបសម្ព័ន្ធទី៤ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ដីកាបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់ត្រូវបញ្ជាក់ឲ្យច្បាស់លាស់ថា ជនជាប់ចោទអាចសុំជំនួយមេធាវី ។ ការបញ្ជូនដីកាកោះត្រូវគោរពចិរវេលាដូចខាងក្រោមៈ

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការ
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងផ្សេងទៀតក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងផ្សេងទៀតក្នុងទឹកដីនៃរដ្ឋជិតខាងនៃព្រះរាជាណាចក្រកម្ពុជា
- ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅកន្លែងផ្សេងពីនេះ
- ប្រសិនបើជនជាប់ចោទត្រូវបានជាប់ឃុំ នោះចិរវេលានេះមិនត្រូវគោរពឡើយ [១៨] ។

ចិរវេលានេះត្រូវតែគោរព បើពុំដូចច្នេះទេនឹងមានមោឃភាពនៃនីតិវិធី លើកលែងតែជនជាប់ចោទយល់ព្រមចូលខ្លួនបង្ហាញដោយស្ម័គ្រចិត្ត ។

### ខ.កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម

វិធីចំណាត់ការបែបនេះមានចែងក្នុងមាត្រា **៤៦** និងមាត្រា **៣០៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ វិធីនេះអនុញ្ញាតឲ្យព្រះរាជអាជ្ញាបង្គាប់ឲ្យជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមៗ នៅចំពោះមុខសាលាដំបូងបន្ទាប់ពីបញ្ចប់ការឃាត់ខ្លួន ដោយកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម [១៩] ។ វិធាននៃនីតិវិធីបែបនេះ មិនត្រូវបានអនុវត្តឡើយចំពោះបទឧក្រិដ្ឋ ឬបទលហុ តែអាចអនុវត្តទៅបានចំពោះបទមជ្ឈិមលុះត្រាតែគោរពលក្ខខណ្ឌមួយចំនួនដូចតទៅៈ

- ប្រភេទចំណាត់ការសំណុំរឿងនេះអាចធ្វើបានតែ ក្នុងករណីបទមជ្ឈិមជាក់ស្តែងប៉ុណ្ណោះ ចំពោះក្នុងករណីផ្សេងទៀតក្រៅពីនេះ គេកំណត់ពីបទមជ្ឈិមដែលអនុញ្ញាតឲ្យអនុវត្តនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម ដោយផ្អែកលើទោសដាក់ពន្ធនាគារដែលសម្រេចដោយតុលាការ។
- ការបង្ហាញខ្លួនភ្លាមអាចអនុវត្តតែចំពោះបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ០១ ឆ្នាំ និងយ៉ាងច្រើន ០៥ ឆ្នាំ ។
- សំណុំរឿងនីតិវិធីត្រូវតែស្ថិតក្នុងស្ថានភាពដែលអាចបញ្ជូនទៅសាលាវិនិច្ឆ័យមានន័យថាបន្ទុកនៃការប្រមូលបានមានគ្រប់គ្រាន់ល្មម ។

[១៨] មាត្រា ៤៥៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[១៩] ឧបសម្ព័ន្ធទី៥ កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម

-ជាចុងក្រោយ បទមជ្ឈិមប្រព្រឹត្តដោយអនីតិជន មិនអាចត្រូវចោទប្រកាន់តាមបែបបទបង្ហាញខ្លួនភ្លាមនោះទេ [២០] ។

__**នីតិវិធី:**__ ពេលបញ្ចប់ការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនត្រូវបញ្ជូនដោយមានកម្លាំងការពារដើម្បីឲ្យចូលខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ។ បន្ទាប់ពីសាកសួរអំពីអត្តសញ្ញាណ ព្រះរាជអាជ្ញាឲ្យដំណឹងទៅជននេះអំពីរឿងរ៉ាវដែលចោទប្រកាន់អំពីកម្មវត្ថុនៃការបង្គារ និងអត្ថបទច្បាប់កំណត់និងបង្ក្រាបបទល្មើស ។ ព្រះរាជអាជ្ញាទទួលស្ដាប់ចម្លើយដោយធ្វើកំណត់សម្គាល់របស់បុគ្គលនោះ ប្រសិនបើជននេះចង់ធ្វើដោយប្រាប់ទៅជននេះថាក្រោមវិធានការបង្គារបែបនេះ ជននេះនឹងត្រូវជំនុំជម្រះនៅក្នុងថ្ងៃនោះតែម្ដងដោយសាលាដំបូង ហើយមានសិទ្ធិទទួលជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬមេធាវីដែលតុលាការចាត់តាំង ។

ការឲ្យដំណឹងអំពីការបង្គារ ដែលធ្វើឡើងដោយកំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺដូចជាដីកាកោះប្រគល់ឲ្យជនជាប់ចោទ ហើយដែលក្នុងខណៈនោះជននេះត្រូវបានទទួលឈ្មោះជា **ជនជាប់ចោទ** ។

តុលាការដែលទទួលបណ្ដឹងតាមកំណត់ហេតុ ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទមុនគេបំផុត និងជាពិសេសត្រូវប្រាប់ជននេះអំពីរយៈពេលដែលជននេះមានដើម្បីរៀបចំការពារខ្លួន ។ ការទាមទារបែបនេះបង្ហាញឲ្យឃើញច្បាស់ថា ដោយសារជនជាប់ចោទពុំមានរយៈពេលដើម្បីការពារខ្លួនចាប់តាំងពីទទួលដំណឹងអំពីការបង្គារ ។ ប្រសិនបើជនជាប់ចោទត្រូវការរយៈពេលដើម្បីរៀបចំការពារខ្លួន តុលាការមានកាតព្វកិច្ចលើករឿងក្ដីទៅជំនុំជម្រះនៅពេលសវនាការលើកក្រោយ ទោះបីខ្លួនយល់ថារឿងក្ដីនេះជំនុំជម្រះភ្លាមបានក៏ដោយ ។ សវនាការអាចបើកក្នុងចិរវេលាមិនឲ្យលើសពីពីរសប្ដាហ៍ ។ ក្នុងការរងចាំការបង្ហាញខ្លួន តុលាការត្រូវសម្រេចឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្នដោយពេញច្បាប់ ។

នៅក្នុងករណីខ្លះ តុលាការជំនុំជម្រះមានសេរីភាពក្នុងវាយតម្លៃស្ថានភាពសំណុំរឿងនីតិវិធី និងអាចសន្និដ្ឋានជាយថាហេតុថារឿងក្ដីនេះពុំអាចជំនុំជម្រះបាននៅឡើយ ។ ដូច្នេះតុលាការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ ។ ជនជាប់ចោទត្រូវតែមកបង្ហាញខ្លួនក្នុងថ្ងៃនោះនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំនោះទេជនជាប់ចោទត្រូវគេដោះលែងឲ្យមានសេរីភាពវិញដោយឯកឯង ។

[២០] មាត្រា ៤៥៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា២០០៧

## ផ្នែកទី២ តួនាទីក្រឡាបញ្ជីក្នុងការទទួល និងថែរក្សាសំណុំរឿង

សំណុំរឿងដែលកសាងឡើងតាមដូចដែលបានលើកឡើងខាងលើ ត្រូវបានបញ្ជូនទៅស្ថាប័នយុត្តាធិការជំនុំជម្រះតាមរយៈលេខាធិកាដ្ឋាននៃតុលាការ (ពីមុនហៅថារដ្ឋបាលនៃតុលាការ) ។ លេខាធិការដ្ឋានតុលាការគឺជាសេនាធិការរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង ដែលគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ក្នុងគោលបំណងដើម្បីធ្វើការសម្រួលការងារនៅតាមសាលាដំបូងនីមួយៗ ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងបំពេញការងាមួយចំនួនផងដែរ [២១] ។ លេខាធិការដ្ឋានត្រូវធ្វើការរៀបចំចុះលេខជំនុំជម្រះ **នៅក្នុងសៀវភៅជំនុំជម្រះ** ដែលប្រធានតុលាការបានប្រគល់ឲ្យ និងចុះលេខលើគម្របសំណុំរឿង ។ ពេលសំណុំរឿងបានចុះលេខហើយ ត្រូវធ្វើការបញ្ជូនសំណុំរឿងទៅចៅក្រមនីមួយៗទទួលបន្ទុកក្នុងការជំនុំជម្រះតាមរយៈដីកាសម្រេច ដែលប្រធានបានធ្វើឡើងកំណត់ក្នុងអំឡុងមួយឆ្នាំម្តង ។ ក្រោយពីបានធ្វើការចាត់តាំងចៅក្រមទទួលបន្ទុកលើសំណុំរឿងរួចរាល់ហើយ សំណុំរឿងត្រូវបានបញ្ជូនមកកាន់បន្ទប់នីមួយៗរបស់ចៅក្រម ។

ក្រោយពីសំណុំរឿងត្រូវបានបញ្ជូនមកដល់បន្ទប់របស់ចៅក្រម តើតួនាទីក្រឡាបញ្ជីត្រូវធ្វើចំណាត់ការយ៉ាងដូចម្តេច?

### កថាខណ្ឌទី១ តួនាទីក្នុងការទទួលសំណុំរឿង

ពេលសំណុំរឿងបានមកដល់ ក្រឡាបញ្ជីដែលនៅបន្ទប់នីមួយៗនៃចៅក្រមត្រូវទទួលសំណុំរឿងទាំងនោះពីក្រឡាបញ្ជី ឬបុគ្គលិករដ្ឋបាលតុលាការដែលបម្រើការនៅលេខាធិការដ្ឋានតុលាការ ។ ក្រឡាបញ្ជីត្រូវធ្វើការទទួលសំណុំរឿងដោយចុះហត្ថលេខាលើ **សៀវភៅស៊ើបសួររបស់លេខាធិការដ្ឋាននៃសាលាដំបូង** ។

#### ក. ការពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារនៅក្នុងសំណុំរឿង

នៅក្នុងការទទួលនូវសំណុំរឿងក្រឡាបញ្ជីត្រូវធ្វើការពិនិត្យមើលទៅលើឯកសារមាននៅក្នុងសំណុំរឿងដែលខ្លួនបានទទួល និងធ្វើការពិនិត្យផ្ទៀងផ្ទាត់រាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿងជាមួយនឹងបញ្ជីរាយលិខិតដែលមាននៅខាងក្នុងនៃក្របសំណុំរឿង ដើម្បីបញ្ជាក់ថាមានលក្ខណៈគ្រប់គ្រាន់ហើយ ឬ យ៉ាងណា [២២] ។ នៅក្នុងការពិនិត្យ និងការផ្ទៀងផ្ទាត់នូវឯកសារក្រឡាបញ្ជីត្រូវធ្វើការពិនិត្យយ៉ាងយកចិត្តទុកដាក់ជាទីបំផុតដើម្បីបង្ការក្នុងករណី ដែលបណ្តាលឲ្យមានការបាត់បង់

[២១] មាត្រា ៤ នៃអនុក្រឹត្យស្តីពីការការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានសាលាដំបូងរាជធានីភ្នំពេញ ។

[២២] ឧបសម្ព័ន្ធទី ៦ បញ្ជីរាយមុខលិខិត

នូវឯកសារណាមួយដោយសារតែភាពចៃដន្យដែលនាំឲ្យមានការបន្ទោសដាក់គ្នាទៅវិញទៅមក ក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវចំពោះភារកិច្ចរបស់ខ្លួន ។

ក្រោយពីបានទទួលយកសំណុំរឿង នឹងផ្ទៀងផ្ទាត់រួចហើយក្រឡាបញ្ជីត្រូវយកសំណុំរឿងនោះចុះនៅក្នុង "**សៀវភៅទទួលរឿងជំនុំជម្រះ**" ដែលសៀវភៅបានមកពីប្រធានតុលាការធ្វើការចែកតាមបន្ទប់នីមួយៗ ។ នៅក្នុងសៀវភៅទទួលសំណុំរឿងជំនុំជម្រះអាចចុះបានទាំងសំណុំរឿងជំនុំជម្រះទោល និង ជំនុំជម្រះក្រុមប្រឹក្សា ។

ការចុះក្នុងសៀវភៅទទួលសំណុំជំនុំជម្រះនោះគឺ ក្នុងគោលបំណងដើម្បីងាយស្រួលក្នុងការតាមដាន និងស្វែងយល់ពីចំណាត់ការនៃសំណុំរឿងនីមួយៗសម្រាប់ទុកធ្វើជារបាយការណ៍ប្រចាំឆ្នាំនូវសំណុំរឿងដែលកំពុងចាត់ការ និងសំណុំរឿងដែលបានចាត់ការជំនុំជម្រះរួចហើយ ។ បន្ទាប់មកក្រឡាបញ្ជីត្រូវយកសំណុំរឿងនោះទៅប្រគល់ជូនចៅក្រមធ្វើការពិនិត្យ និងធ្វើការបែងចែកសំណុំរឿងនោះទៅក្រឡាបញ្ជីនៅក្នុងបន្ទប់ទៅតាមការពិភាក្សាគ្នារវាងចៅក្រម និងក្រឡាបញ្ជី ប្រសិនបើក្នុងករណីមានក្រឡាបញ្ជីច្រើននាក់ ។

### ខ.តួនាទីក្នុងការរក្សាទុកសំណុំរឿង

នៅពេលសំណុំរឿងត្រូវបានចៅក្រមសម្រេចប្រគល់អោយក្រឡាបញ្ជីណាម្នាក់ទទួលយកទៅចាត់ការរួចហើយ សំណុំរឿងត្រូវបានក្រឡាបញ្ជីយកទៅរក្សាទុកនូវនៅកន្លែងមានសុវត្ថិភាព និងមានលក្ខណៈត្រឹមត្រូវដូចជា នៅក្នុងបន្ទប់ធ្វើការរបស់ក្រឡាបញ្ជី ឬកន្លែងណាមួយនៃតុលាការដែលជាកន្លែងមានសុវត្ថិភាព និងងាយស្រួលក្នុងការរកផងដែរ ។

សំណុំរឿងនីមួយៗ ក្រឡាបញ្ជីត្រូវធ្វើការថតចម្លងនូវប្រភេទឯកសារដែលមាននៅក្នុងសំណុំរឿងតាមលទ្ធភាព និងបញ្ជាក់ថាត្រូវតាមច្បាប់ដើមដើម្បីទុកជាឯកសារបង្ការទុក ។ នៅមុនពេលសវនាការមេធាវីអាចត្រួតពិនិត្យមើលសំណុំរឿងនៅក្នុងការិយាល័យក្រឡាបញ្ជីនៃតុលាការ ។ មេធាវី ឬ លេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឲ្យធ្វើការចម្លងលិខិតសំណុំរឿងដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី [២៣] ។

## កថាខណ្ឌទី២ តួនាទីក្នុងព្រាងដីកា និងលិខិតផ្សេងៗ

ក្រឡាបញ្ជីបានទទួលធ្វើចំណាត់ការលើសំណុំរឿង ត្រូវធ្វើការពិនិត្យមើលឯកសារដែលមាននៅក្នុងសំណុំរឿងមើលថា តើមានភាគីណាខ្លះដែលមាននៅក្នុងរឿងដូចជា៖ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី អ្នកជំនាញ .ល. ។ ការពិនិត្យទៅលើឯកសារនេះគឺដើម្បីសិក្សាអំពីអង្គហេតុដែលកើតមានឡើង រីឯការពិនិត្យទៅលើភាគីក្នុងគោលបំណង

[២៣] មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដើម្បីធ្វើការព្រាងដីកា និងលិខិតផ្សេងៗសម្រាប់ជូនដំណឹងអំពីថ្ងៃបើកសវនាការ ។ ប៉ុន្តែមុននឹងធ្វើការព្រាងដីកាទាំងនោះក្រឡាបញ្ជីត្រូវដឹងពីកាលបរិច្ឆេទនៃការជំនុំជម្រះជាមុនសិន ។

តើការកំណត់កាលបរិច្ឆេទនៃការជំនុំជម្រះត្រូវកំណត់យ៉ាងដូចម្តេច ? តើប្រភេទដីកា និងលិខិតអ្វីខ្លះដែលត្រូវព្រាងប្រើសម្រាប់ការជូនដំណឹងនេះ ? ដីកា និងលិខិតដែលត្រូវព្រាងប្រើសម្រាប់សវនាការជាសមត្ថកិច្ចរបស់នរណា ?

**ក. ការត្រួតពិនិត្យកាលបរិច្ឆេទនៃការជំនុំជម្រះ**

លើកលែងតែករណីនៃនីតិវិធីក្នុងការចូលបង្ហាញខ្លួនភ្លាម (ដែលត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង) កាលបរិច្ឆេទនៃសវនាការលើរឿងក្តីព្រហ្មទណ្ឌទាំងអស់ត្រូវកំណត់ដោយប្រធានតុលាការ ។ នៅក្នុងករណីដែលក្រឡាបញ្ជីបានទទួលសំណុំរឿងពីការចាត់តាំងរបស់ចៅក្រមជំនុំជម្រះរួចហើយ ក្រឡាបញ្ជី ត្រូវតែពិនិត្យមើលទៅលើកាលវិភាគដែលប្រធានតុលាការបានកំណត់តាមរយៈដីកាសម្រេចប្រចាំឆ្នាំ ហើយទៅជម្រាបប្រាប់ចៅក្រមអំពីថ្ងៃដែលត្រូវជំនុំជម្រះ ដោយគោរពតាមថេរវេលាដូចមានចែងនៅក្នុងមាត្រា **៤៥៧** (រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងដីកាបង្គាប់ឲ្យចូលបង្ហាញខ្លួន) និងមាត្រា **៤៦៦** (រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅ និងដីកាបង្គាប់ឲ្យចូលបង្ហាញខ្លួន) នៃក្រមនេះដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ ។

តាមពិតការកំណត់ថ្ងៃសវនាការជាក់លាក់ គឺជាការសម្រេចរបស់ចៅក្រមជំនុំជម្រះនីមួយៗដោយអាស្រ័យទៅលើការកោះហៅជនជាប់ចោទមកកាន់តុលាការ ។ ចំពោះការកំណត់ថ្ងៃរបស់ប្រធានតុលាការ គឺអាស្រ័យដោយសារសាលសវនាការមានចំនួនតិចហើយការធ្វើបែបនេះ គឺដើម្បីបញ្ចៀសកុំឲ្យមានភាពជូនថ្ងៃគ្នានៃការជំនុំជម្រះរបស់ចៅក្រម [២៤] ។

កាលបរិច្ឆេទនេះត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា [២៥]។

**ខ.ប្រភេទដីកា និងលិខិតដែលត្រូវព្រាង**

នៅពេលដែលចៅក្រមយល់ឃើញថា សំណុំរឿងនោះមានលក្ខណៈពេញលេញចប់សព្វគ្រប់ និងបានកំណត់កាលបរិច្ឆេទនៃការជំនុំជម្រះរួចរាល់ហើយ ចៅក្រមនឹងបង្គាប់ឲ្យក្រឡាបញ្ជីកាន់សំណុំរឿងនោះធ្វើការព្រាងដីកា ឬ លិខិតមួយចំនួនដូចជា:

- លិខិតស្នើសុំតំណាងអយ្យការចូលរួមជំនុំជម្រះ [២៦] ។

[២៤] ឧបសម្ព័ន្ធទី៧ តាងរាងកាលវិភាគសវនាការ

[២៥] មាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២៦]ឧបសម្ព័ន្ធទី៨ សំណើសុំតំណាងអយ្យការចូលរួមសវនាការ

- ដីកាបង្គាប់ឲ្យជនជាប់ចោទចូលមកសវនាការ (ករណីជនជាប់ចោទនៅក្រៅឃុំ) ឬដីកាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទមកសវនាការ( ករណីជនជាប់ចោទនៅក្នុងឃុំ( [២៧] ។

- ដីកាកោះហៅជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី ជាដើម [២៨] ។

- ដីកាចាត់តាំងមេធាវី (ក្នុងករណីបទឧក្រិដ្ឋ ឬជនជាប់ចោទជាអនីតិជន ប្រសិនបើជនជាប់ចោទនោះមិនបានពឹងពាក់មេធាវីដោយខ្លួនឯង ) [២៩] ។

- លិខិតអញ្ជើញមេធាវី លិខិតអញ្ជើញអ្នកជំនាញ និងអ្នកបកប្រែ [៣០] ។

- លិខិតបែបបទរដ្ឋបាលផ្សេងទៀត ប្រសិនបើមានការចាំបាច់ ។

**គ. សមត្ថកិច្ចក្នុងការតែងនិពន្ធ និងទម្រង់បែបបទនៃដីកាកោះ**

ដីកាកោះហៅឲ្យចូលក្នុងសវនាការមានការតាក់តែងខុសៗគ្នាដូចជា ដីកាកោះហៅជនជាប់ចោទឲ្យចូលសវនាការ ,ដីកាកោះហៅជនក្រៅពីជនជាប់ចោទឲ្យចូលសវនាការ ។ ការតាក់តែងដីកាកោះហៅឲ្យចូលសវនាការ មិនមានការកំណត់អំពីការតែងនិពន្ធជាក់លាក់ទេនៅក្នុងច្បាប់នោះទេ តែមានកំណត់ជាក់លាក់តែអំពីនិទ្ទេសដែលត្រូវចុះក្នុងដីកាតែប៉ុណ្ណោះ ហើយនិទ្ទេសដែលត្រូវចុះក៏មានលក្ខណៈខុសៗគ្នាដែរ ។

ជាក់ស្តែង៖ ដីកាកោះហៅជនជាប់ចោទឲ្យចូលសវនាការ ត្រូវមាននិទ្ទេសដូចតទៅ៖

-អត្តសញ្ញាណជនជាប់ចោទ

-កាលបរិច្ឆេទ និងទីកន្លែងកំណើតនៃជនជាប់ចោទ

-លំនៅឋាននៃជនជាប់ចោទដែល

-ការយោងដីកា ឬសាលដីកាបញ្ជូន

-តុលាការដែលទទួលបណ្តឹងដើម្បីជំនុំជម្រះ

-ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

-កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ។

-ក្នុងដីកាត្រូវបញ្ជាក់ថា ជនជាប់ចោទអាចអមដោយមេធាវីជានិច្ច [៣១] ។

[២៧] ឧបសម្ព័ន្ធទី៩ ដីកាបង្គាប់អោយជនជាប់ចោទចូលមកជំនុំជម្រះ

[២៨] ឧបសម្ព័ន្ធទី១០ ដីកាកោះហៅ

[២៩] ឧបសម្ព័ន្ធទី១១ ដីកាចាត់តាំងមេធាវី

[៣០] ឧបសម្ព័ន្ធទី១២ លិខិតអញ្ជើញ

[៣១] មាត្រា ៤៦៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

គ្រប់សវនាការទាំងអស់ការតាក់តែងរៀបចំដីកាកោះហៅឲ្យចូលសវនាការ ឬ លិខិតអញ្ជើញ ជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញានោះទេ ។ ប៉ុន្តែដោយសារជាក់ស្តែងសំណុំរឿងស្ថិតនៅក្នុងចំណាត់ការរបស់ក្រឡាបញ្ជីសវនាការ ហើយដើម្បីមានភាពងាយស្រួល និងឆាប់រហ័ស ទើបរាល់ការតែងនិពន្ធដីកាកោះត្រូវបានក្រឡាបញ្ជីសវនាការជាអ្នករៀបចំទៅវិញ ។ ក្រោយពីបានធ្វើការព្រាងដីការួចរាល់ហើយ ក្រឡាបញ្ជីត្រូវយកដីកាទាំងនោះទៅសុំហត្ថលេខាពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងដែលត្រូវចូលរួមជំនុំជម្រះក្នុងសំណុំរឿងនោះ ។

ក្រោយពីយកទៅសុំហត្ថលេខាពីតំណាងអយ្យការហើយ ក្រឡាបញ្ជីត្រូវយកដីកាទាំងនោះយកទៅចុះលេខនៅក្នុងសៀវភៅចុះលេខដីកា ដែលមាននៅលេខាធិការដ្ឋាននៃសាលាដំបូងហើយ ចាត់ចែងប្រគល់ដល់ស្ថាប័នមានសមត្ថកិច្ច ឬ មន្ត្រីដែលមានសមត្ថកិច្ចទទួលប្រតិបត្តិកិច្ចការបញ្ជូនដីកាកោះហៅនោះ។

## កថាខណ្ឌទី ៣ ការបញ្ជូនដីកាកោះហៅឲ្យចូលសវនាការ

ការបញ្ជូន គឺជាការជូនដំណឹងអំពីការកោះហៅ ឬ ឯកសារសេចក្តីសម្រេចផ្សេងៗរបស់តុលាការទៅភាគីពាក់ព័ន្ធតាមនីតិវិធីដែលច្បាប់ដែលបានកំណត់ដោយភ្ជាប់ជាមួយនូវអានុភាពគតិយុត្តិផ្សេងៗ ។ ចំពោះការបញ្ជូនត្រូវគោរពនូវនីតិវិធីបញ្ជូនទៅបុគ្គលដែលទទួលការបញ្ជូន សមត្ថកិច្ចប្រតិបត្តិកិច្ចការបញ្ជូន រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅ និងទម្រង់ការផ្សេងៗទើបការបញ្ជូនមានអានុភាពគតិយុត្តិដែលអាចឲ្យតុលាការបន្តនីតិវិធីដំណើរការនៃការដោះស្រាយរឿងក្តីទៅមុខបានប្រកបដោយយុតិធម៌ ។

មុននឹងធ្វើការបញ្ជូននូវដីកាកោះ យើងត្រូវយល់ដឹងអំពី ស្ថាប័នដែលត្រូវប្រតិបត្តិកិច្ចការបញ្ជូន (ក) និងនីតិវិធីនៃការបញ្ជូនផងដែរ(ខ) ។

### ក.ស្ថាប័នអនុវត្តនូវកិច្ចការបញ្ជូន

ស្ថាប័នអនុវត្តកិច្ចការបញ្ជូនដីកាកោះហៅរួមមាន មន្ត្រីមានសមត្ថកិច្ចអនុវត្តកិច្ចការបញ្ជូន(១) និងមន្ត្រីទទួលសមត្ថកិច្ចអនុវត្តកិច្ចការបញ្ជូន(២) ។

១.មន្ត្រីមានសមត្ថកិច្ចអនុវត្តកិច្ចការបញ្ជូន

មន្ត្រីមានសមត្ថកិច្ច ដែលច្បាប់បានផ្តល់សិទ្ធិអំណាចឲ្យក្នុងការអនុវត្តកិច្ចការបញ្ជូនដីកាកោះហៅឲ្យចូលសវនាការមាន៖ ព្រះរាជអាជ្ញា និងអាជ្ញាសាលា។

-ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ជាតំណាងអង្គការអយ្យការអមសាលាដំបូង ។ ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចឋានានុក្រមរបស់ព្រះរាជអាជ្ញា អាចប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើស [៣២] ។

[៣២] មាត្រា ៣៦ និងមាត្រា៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ដីកាកោះហៅឲ្យចូលសវនាការ ព្រះរាជអាជ្ញាអាចប្រគល់ឲ្យដល់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋវេណី សាក្សី និងជនដែលពាក់ព័ន្ធផ្សេងទៀតដោយផ្ទាល់ដៃ [៣៣] ។ ក្នុងករណីនេះព្រះរាជអាជ្ញាប្រគល់ដីកាកោះឲ្យដល់ជនទាំងនោះ ។ ព្រះរាជអាជ្ញាចុះនិទ្ទេសលើដីកាអំពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ ។ ជនដែលទទួលដីកាត្រូវចុះហត្ថលេខានៅដើមដីកាកោះនោះ ។ ចំពោះចុងដីកាកោះ ឬដើមដីកាកោះ គឺសម្គាល់ដោយការចុះនៅលើរឹមទំព័រនៃដីកាកោះ។ ដោយឡែកក្នុងករណីជនដែលត្រូវទទួលបានអវត្តមានមិននៅលំនៅឋាន ឬ ក្នុងករណីមិនព្រមទទួលដីកាកោះហៅជាដើម ច្បាប់មិនបានបញ្ញត្តិថាត្រូវធ្វើយ៉ាងដូចម្តេចនោះទេ ។

ចំពោះជនជាប់ចោទដែលត្រូវបានឃុំខ្លួននៅពន្ធនាគារវិញ ព្រះរាជអាជ្ញាធ្វើការបញ្ជូនតាមរយៈប្រធានពន្ធនាគារ ។

- អាជ្ញាសាលា គឺជាមន្ត្រីរាជការក្នុងក្រមខណ្ឌក្រសួងយុត្តិធម៌ ហើយត្រូវបំពេញការងារនៅតាមសាលាដំបូង សាលាឧទ្ធរណ៍ ឬ តុលាការកំពូល តាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ [៣៤] ។ ក្រៅពីព្រះរាជអាជ្ញា ដីកាកោះហៅក៏អាចប្រគល់ដល់ជនដែលត្រូវទទួលដោយអាជ្ញាសាលាផងដែរ ។ ក្នុងករណីនេះអាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយ ដើម្បីប្រគល់ដីកាកោះហៅដល់ជនដែលពាក់ព័ន្ធដោយផ្ទាល់ដៃ ។ ប្រសិនបើអាជ្ញាសាលាជួបប្រទះជនដែលត្រូវប្រគល់នោះនៅលំនៅឋាន ឬកន្លែងដទៃទៀត អាជ្ញាសាលាអាចប្រគល់ដីកាកោះឲ្យជននោះបាន ។ អាជ្ញាសាលាចារនៅលើដើមដីកាកោះហៅថាចុងដីកាត្រូវបានប្រគល់ឲ្យដល់ដៃជនទាំងនោះដោយផ្ទាល់ដៃ ហើយត្រូវចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះនោះ និងឲ្យជននោះចុះហត្ថលេខានៅលើដើមដីការួចហើយបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាម ។ នៅក្នុងគ្រប់ករណីដែលតម្រូវឲ្យមានការចុះហត្ថលេខារបស់អ្នកទទួលនៅលើលិខិតណាមួយ ហត្ថលេខានេះអាចត្រូវបានជំនួសដោយការផ្តិតម្រាមដៃ ប្រសិនបើបុគ្គលនោះមិនចេះចុះហត្ថលេខា ។

នៅក្នុងករណីជនដែលត្រូវទទួលពុំមានវត្តមាននៅក្នុងលំនៅឋាន គឺអាជ្ញាសាលាអាចប្រគល់ចុងដីកាកោះឲ្យទៅបុគ្គលទាំងណា ដល់នីតិភាពដែលមានវត្តមាននៅក្នុងលំនៅឋាននោះ ហើយចារនៅលើដើមដីកាកោះថាចុងដីកាកោះ ត្រូវបានប្រគល់ឲ្យដល់បុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋានជាមួយ ត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ ឲ្យបុគ្គលដែលទទួលនោះចុះហត្ថលេខានៅដើមដីកា និងឲ្យបុគ្គលនោះសន្យាថានឹងប្រគល់ដីកានោះដល់ជនជាប់ចោទ (នៅក្រៅឃុំ) ឬសាក្សី...ក្នុងរយៈដល់ខ្លីបំផុត ។ ប្រសិនបើអាជ្ញាសាលា

[៣៣] មាត្រា ៤៥៨ និងមាត្រា៤៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[៣៤] មាត្រា៤ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលាឆ្នាំ២០១២

បានចុះទៅដល់លំនៅឋានរបស់ជនដែលពាក់ព័ន្ធហើយ តែជនទាំងនោះមិនព្រមទទួលដីកាកោះ ឬ គ្មានបុគ្គលណាម្នាក់នៅក្នុងលំនៅឋាននោះទេ ឬ គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុង លំនៅឋានព្រមទទួលដីកានោះទេ អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះនោះឲ្យដល់មេឃុំ ឬចៅ សង្កាត់ ឬជំទប់ ឬចៅសង្កាត់រងណាមួយ ហើយចារលើដើមដីកាកោះអំពីអត្តសញ្ញាណ និងឋានៈ របស់បុគ្គលដែលទទួល ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ ហើយឲ្យបុគ្គលនោះចុះហត្ថលេខា និងសន្យាថានឹងប្រគល់ដីកាឲ្យដល់បុគ្គលដែលត្រូវទទួលក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ ដើមដីកា ត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាម ។

ដោយហេតុថាអាជ្ញាសាលាក្នុងស្ថានភាពបច្ចុប្បន្នពុំទាន់មាននៅឡើយទេ ( កំពុងរងចាំច្បាប់ ស្តីពីអាជ្ញាសាលា ) ទើបមានប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាលេខ ៣០ កយ/០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ដែលផ្តល់តួនាទីដលព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង អនុវត្តកិច្ចការអាជ្ញាសាលាដែលកំណត់ក្នុងច្បាប់ផ្សេងៗស្ថិតនៅក្នុងសមត្ថកិច្ច នៃសាលាដំបូងដែលខ្លួនស្ថិត នៅក្រោមរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីអាជ្ញាសាលា ។

នៅក្នុងទិដ្ឋភាពនៃការអនុវត្តជាក់ស្តែងស្ទើរគ្រប់ករណីទាំងអស់ នៃការប្រតិបត្តិកិច្ចការបញ្ជូន របស់ព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារង ពុំដែលធ្វើដោយខ្លួនឯងផ្ទាល់នោះទេ ទោះបីជាច្បាប់បាន ផ្តល់តួនាទីដល់ស្ថាប័ននេះក៏ដោយ ។ ចំពោះការប្រតិបត្តិកិច្ចការបញ្ជូនដីកាកោះហៅដែលច្បាប់ បានផ្តល់តួនាទីដល់អាជ្ញាសាលា គឺដូចបានបកស្រាយខាងលើរួចមកហើយ គឺពុំទាន់មានអាជ្ញា សាលានៅឡើយទេ ។ ដូច្នេះ ការប្រតិបត្តិកិច្ចការបញ្ជូនដីកាកោះហៅឲ្យចូលសវនាការក្នុងរឿង ព្រហ្មទណ្ឌត្រូវបានប្រតិបត្តិដោយមន្ត្រីទទួលសមត្ថកិច្ចការបញ្ជូនវិញ ។

### ២. មន្ត្រីទទួលសមត្ថកិច្ចការបញ្ជូន

មន្ត្រីទទួលសមត្ថកិច្ច ដែលច្បាប់ផ្តល់សិទ្ធិអំណាចឲ្យក្នុងការអនុវត្តកិច្ចការបញ្ជូនដីកាកោះ ហៅរួមមាន៖ ក្រឡាបញ្ជី [៣៥] មន្ត្រីរដ្ឋបាលតាមសាលាជម្រះក្តីនីមួយៗ ប្រធានពន្ធនាគារ ឬមណ្ឌល ឃុំខ្លួន មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថ [៣៦]។

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថដែល ព្រះរាជអាជ្ញាសុំឲ្យប្រគល់ដីកាកោះ ត្រូវតែគោរពតាមបទបញ្ជាព្រះរាជអាជ្ញា ។ ចំពោះករណីដែល សាក្សីនៅក្នុងពន្ធនាគារដោយជាប់ឃុំពីរឿងអ្វីផ្សេង គឺការកោះហៅជននោះតាមរយៈប្រធានពន្ធនាគារ ឬប្រធានមណ្ឌលឃុំខ្លួន ។ ចំពោះបែបបទត្រូវធ្វើនិងនីតិវិធីប្រតិបត្តិកិច្ចការបញ្ជូនគឺអនុវត្តដូចគ្នានឹង

---

[៣៥] ជាអ្នកបច្ចេកទេសផ្នែកនីតិវិធីដែលជួយដល់ចៅក្រមនៅក្នុងសកម្មភាពសាលាជម្រះក្តីទៅតាមលក្ខខណ្ឌដែលមានកំណត់ ក្នុងអត្ថបទច្បាប់ ឬបទបញ្ញាជាធរមាន (មាត្រា ២ នៃសេចក្តីព្រាងច្បាប់ស្តីលក្ខន្តិកៈដោយឡែករបស់ក្រឡាបញ្ជីឆ្នាំ២០១៦)

[៣៦] មាត្រា៤៦៣ ,៤៧២ និងមាត្រា៤៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ការបញ្ជូនដែលធ្វើឡើងដោយព្រះរាជអាជ្ញា និងអាជ្ញាសាលាផងដែរ [៣៧] ។ កាលណាដីកាកោះហៅឲ្យចូលសវនាការត្រូវបានប្រគល់ដោយអាជ្ញាសាលា ក្រឡាបញ្ជី តាមផ្លូវរដ្ឋបាល ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឬតាមរយៈនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ គឺដីកាកោះហៅនោះត្រូវបានចុះនិទ្ទេសដូចខាងក្រោមៈ

- អត្តសញ្ញាណ និងឋានៈរបស់អ្នកប្រគល់ដីកា
- ហត្ថលេខារបស់អ្នកប្រគល់ដីកា។

ជាការសង្កេតរួមសម្រាប់មន្ត្រីមានសមត្ថកិច្ច ឬមន្ត្រីទទួលសមត្ថកិច្ច ដែលមានតួនាទីប្រតិបត្តិកិច្ចការបញ្ជូនដីកាកោះហៅជនជាប់ចោទ សាក្សីឲ្យចូលសវនាការ ជាបញ្ហាត្រង់ថាក្នុងករណីដែលសាក្សីគ្មានលំនៅឋានឬទីសំណាក់ ឬសាក្សីដែលរស់នៅក្រៅដែនដីជាតិ គឺបទបញ្ញត្តិច្បាប់មិនបានកំណត់ពីបែបបទនិងនីតិវិធីនៃការកោះហៅក្នុងករណីទាំងអស់នេះនោះទេ ។

ដោយឡែកចំពោះរយៈពេលបញ្ជូនដីកាកោះសាក្សីឲ្យចូលសវនាការ គឺពុំមានបញ្ញត្តិច្បាប់កំណត់ពីរយៈពេលដែលត្រូវគោរពរវាងការកោះហៅ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនរបស់សាក្សីដូចករណីជនជាប់ចោទនោះទេ ព្រោះក្នុងមាត្រា **៤៨១** ស្ដីពីបទបញ្ញត្តិរួម នៃក្រមនីតិវិធីព្រហ្មទណ្ឌគឺមិនមានវិសាលភាពគ្របដណ្ដប់ដល់ការអនុវត្តដូចគ្នាចំពោះមាត្រា **៤៦៦** (រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងបង្គាប់ឲ្យចូលបង្ហាញខ្លួន) និងមាត្រា **៤៥៧** (រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងបង្គាប់ឲ្យចូលបង្ហាញខ្លួន)នោះទេ ។

នៅគ្រប់ករណីទាំងអស់លិខិតចម្លងមួយច្បាប់នៃដីកា ឬសាលដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះត្រូវភ្ជាប់ជាមួយនឹងចុងដីកាកោះហៅសាក្សី [៣៨] ។

### ខ. នីតិវិធីនៃការបញ្ជូនដីកាកោះហៅ

នៅក្នុងការអនុវត្តជាក់ស្ដែង នៅគ្រប់ករណីទាំងអស់នៃសវនាការ ក្រឡាបញ្ជីទទួលបន្ទុកកាន់សំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះបានប្រើប្រាស់គ្រប់មធ្យោបាយ ។ ចំពោះជនជាប់ចោទដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ក្រឡាបញ្ជីត្រូវបញ្ជូនដីកាបង្គាប់ឲ្យនាំជនជាប់ចោទចូលសវនាការតាមរយៈ ប្រធានពន្ធនាគារ ។ យើងឃើញថានៅសាលាដំបូងរាជធានីភ្នំពេញនៅក្នុងការបញ្ជូនដីកា មានមន្ត្រីពន្ធនាគារនៅប្រចាំនៅក្នុងសាលាដំបូងក្រឡាបញ្ជីត្រូវយកដីកានោះទៅប្រគល់ឲ្យមន្ត្រីពន្ធនាគារដោយឲ្យចារទទួលរួចយកដីកានោះដាក់ចូលក្នុងសំណុំរឿងវិញ ។

---

[៣៧] មាត្រា ៤៨១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[៣៨] មាត្រា ៤៧៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

នៅក្នុងករណីការកោះហៅជនជាប់ចោទដែលនៅក្រៅពន្ធនាគារ គឺក្រឡាបញ្ជីប្រើជម្រើសបីយ៉ាងក្នុងការកោះហៅ គឺៈ

-អនុវត្តកិច្ចការបញ្ជូនដោយខ្លួនឯងផ្ទាល់ក្នុងនាមជាមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន តាមរយៈមធ្យោបាយ ទំនាក់ទំនងតាមទូរស័ព្ទដល់ជនដែលត្រូវទទួល ឲ្យមកយកដីកាកោះហៅឲ្យចូលសវនាការនៅទីកន្លែងណាមួយដោយប្រគល់ដីកាកោះដល់ដៃជននោះ ហើយចុះកាលបរិច្ឆេទនៅលើដើមដីកាអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការបញ្ជូន និងឲ្យសាក្សីចុះហត្ថលេខាលើដើមដីកានោះ ។

-មិនបញ្ជូនដីកាកោះនោះដោយផ្ទាល់ដៃនោះទេ គឺធ្វើការបញ្ជូនដីកាតាមរយៈមន្ត្រីនគរបាលទទួលបន្ទុកកិច្ចការបញ្ជូនដីកាកោះក្នុងរឿងព្រហ្មទណ្ឌដោយក្រឡាបញ្ជីធ្វើការទំនាក់ទំនងទៅមន្ត្រីនគរបាលដែលតុលាការតែងតាំងជាអ្នករត់ដីកានៅតាមខណ្ឌនីមួយៗ ដោយផ្ទាល់ធ្វើការបញ្ជូនដីកាកោះតែម្តង [៣៩] ។ ក្រឡាបញ្ជីត្រូវឲ្យនគរបាលទទួលបន្ទុកបញ្ជូនដីកាកោះហៅចុះហត្ថលេខាទទួលលើដីកាកោះហៅមួយសន្លឹក និងប្រគល់ដីកាកោះហៅពីរសន្លឹក (ដើមដីកា និងចុងដីកា) ដល់មន្ត្រីនគរបាលរត់ដីកាដើម្បីយកទៅប្រគល់ឲ្យជនដែលត្រូវទទួលនូវចុងដីកាកោះ ហើយបង្វិលដើមដីកាកោះដែលមានចុះនិទ្ទេសពីការបញ្ជូនមកក្រឡាបញ្ជីវិញ ឲ្យបានមុនកាលកំណត់របស់ចៅក្រម ឬក្រុមប្រឹក្សាដាក់ក្នុងសំណុំរឿង ។

-បញ្ជូនដីកាកោះហៅ ដោយមានដីកាបញ្ជូនលិខិតទៅព្រះរាជអាជ្ញានៃដែនដីដែលជនជាប់ចោទរស់នៅ តាមរយៈប្រៃសណីយ៍ដើម្បីចាត់ការបញ្ជូនដល់ជននោះ [៤០] ។ បន្ទាប់ពីប្រតិបត្តិការរួចហើយ ដើមដីកាកោះហៅដែលមាននិទ្ទេសចុះស្តីពីការបញ្ជូន ត្រូវបង្វិលមកក្រឡាបញ្ជីវិញឲ្យបានមុនការកំណត់របស់ចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះ។ លើសពីនេះប្រសិនបើជនជាសាក្សីរស់នៅក្រៅដែនដីជាតិ ការកោះហៅជននោះចូលសវនាការគឺ ក្រឡាបញ្ជីធ្វើការបញ្ជូនដីកាកោះហៅអមជាមួយលិខិតរដ្ឋបាលទៅក្រសួងយុត្តិធម៌ ដើម្បីបញ្ជូនដីកាកោះហៅទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់ការបញ្ជូនបន្តទៅឯកអគ្គរាជទូតប្រចាំប្រទេសដែលជនជាប់ចោទកំពុងរស់នៅ ។ ក្រោយពីប្រតិបត្តិការរួចហើយ ដើមដីកាកោះហៅដែលមាននិទ្ទេសចុះស្តីពីការបញ្ជូន ត្រូវបង្វិលមកក្រឡាបញ្ជីវិញឲ្យបានមុនការកំណត់របស់ចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះ។

ដោយឡែកចំពោះករណីដែលកោះហៅសាក្សីវិញ ប្រសិនបើសាក្សីស្ថិតនៅក្នុងពន្ធនាគារ ក្រឡាបញ្ជី បញ្ជូនដីកាកោះហៅជនជាសាក្សី តាមរយៈប្រធានពន្ធនាគារ ដោយបង្គាប់ឲ្យនាំជនជាសាក្សីចូលសវនាការ ។ ដីកាកោះហៅសាក្សីត្រូវបានប្រគល់ឲ្យដល់ដៃជនជាសាក្សីដោយប្រធាន

---

[៣៩] ឧបសម្ព័ន្ធទី១៣ បញ្ជីមន្ត្រីទទួលបន្ទុកក្នុងកិច្ចការបញ្ជូន

[៤០] នាយកដ្ឋានប្រៃសណីយ៍នៃក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍,បង្កាន់ដៃលេខ០៣២៦៣ (ភ្ជាប់ឧបសម្ព័ន្ធ១៤)

ពន្ធនាគារ ។ ចំពោះការកោះហៅសាក្សដែលស្ថិតនៅ ក្រៅពន្ធនាគា ក្រឡាបញ្ជីត្រូវធ្វើការកោះហៅតាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនដែលសាលាដំបូងបានចាត់តាំង ឬតាមរយៈប្រៃនីយ៍ ឬតាមមធ្យោបាយផ្សេងៗទៀត ។ នៅក្នុងការអនុវត្តជាក់ស្តែង រយៈពេលនៃការបញ្ជូនដីកាកោះហៅសាក្សីគឺអនុលោមទាំងស្រុង ទៅតាមរយៈពេលដែលកោះហៅជនជាប់ចោទឲ្យចូលសវនាការដែរ ។ ហេតុផលដែលនាំឲ្យមានការអនុវត្តបែបនេះ ដោយសារតែការចុះហត្ថលេខារបស់ព្រះរាជអាជ្ញា និងការផ្ញើដីកាកោះហៅចេញក្នុងកាលបរិច្ឆេទតែមួយ និងហេតុផលផ្សេងៗទៀត ។

# ជំពូកទី២
# តួនាទីក្រឡាបញ្ជីក្នុងដំណាក់កាលចាប់ផ្តើមសវនាការ

នៅពេលថ្ងៃចាប់ផ្តើមបើកសវនាការបានមកដល់ក្រឡាបញ្ជី មានតួនាទីជាច្រើនទាំងនៅមុនពេលចាប់ផ្តើមបើកសវនាការ និងទាំងអំឡុងពេលសវនាការ ដូចជាការរៀបចំបន្ទប់សាលសវនាការ ការត្រួតពិនិត្យអ្នកចូលរួម ការសរសេរកំណត់ហេតុ និងតួនាទីមួយចំនួនទៀត ទោះបីជាច្បាប់មិនបានកំណត់ឲ្យបានជាក់លាក់ក៏ដោយ ដោយការអនុវត្តក្រឡាបញ្ជីមានតួនាទីដូចរៀបរាប់ខាងក្រោមនេះ ។

## ផ្នែកទី១ តួនាទីក្រឡាបញ្ជីមុនពេលប្រកាសបើកសវនាការ

នៅពេលថ្ងៃសវនាការមកដល់ មុនពេលចាប់ផ្តើមប្រកាសបើកសវនាការក្រឡាបញ្ជីត្រូវរៀបចំនូវសំណុំរឿងដែលលើកយកមកជំនុំជម្រះព្រមទាំង **"សៀវភៅកំណត់ហេតុសវនាការ"** ឲ្យរួចជាស្រេចនឹងចុះមករៀបចំ និងត្រួតពិនិត្យនូវបន្ទប់សវនាការ **(កថាខណ្ឌទី១)** ដែលមានការរៀបចំទុកដាក់ភស្តុតាង ការរៀបចំតុក្រចកសេះ និងព្រមទាំងការរៀបចំបន្ទប់សម្រាប់ជនជាប់ចោទ និងសាក្សីផងដែរ ។ ក្រៅពីនេះក្រឡាបញ្ជីត្រូវធ្វើការរៀបចំផ្នែកសន្តិសុខ **(កថាខណ្ឌទី២)** ដោយធ្វើការត្រួតពិនិត្យនូវអត្តសញ្ញាណជនដែលបានចូលរួមនៅក្នុងពេលសវនាការ ការរៀបចំនូវលិខិតរដ្ឋបាលស្នើសុំកម្លាំងមកការពារនៅពេលមានរឿងកើតឡើង និងការរៀបចំដឹកនាំធ្វើសម្បថជាដើម ។

### កថាខណ្ឌទី១ ការរៀបចំបន្ទប់នៃសាលសវនាការ

បច្ចុប្បន្ននៅតាមសាលាជម្រះក្តីនីមួយៗនៅក្នុងប្រទេសកម្ពុជា តែងតែមានបន្ទប់សាលសវនាការសម្រាប់ដំណើរការជំនុំជម្រះ ។ ជាក់ស្តែងនៅសាលាដំបូងរាជធានីភ្នំពេញបន្ទប់សាលសវនាការចំនួន ០៥ (ប្រាំ)បន្ទប់ សម្រាប់ការជំនុំជម្រះដែលក្នុងនោះបន្ទប់សាលសវនាការចំនួន០៤(បួន)ជាបន្ទប់សាលសវនាការសម្រាប់ការជំនុំជម្រះរឿងក្តី ដែលបានធ្វើការកំណត់ជាស្រេចរបស់ប្រធានតុលាការ និង ០១ (មួយ) បន្ទប់ទៀតសម្រាប់ជាជំនុំជម្រះផ្ទាល់ ។ នៅមុនពេលធ្វើការជំនុំជម្រះក្រឡាបញ្ជីត្រូវចុះមកធ្វើការត្រួតពិនិត្យ និង រៀបចំបន្ទប់សវនាការដែលត្រូវបានកំណត់តាមកាលបរិច្ឆេទនៃសាលាដំបូង រាជធានី-ខេត្ត ឲ្យមានរបៀបរយហើយត្រូវត្រួតពិនិត្យមើលសម្ភារៈមួយចំនួននៅក្នុងបន្ទប់សវនាការដូចខាងក្រោម ៖

-ពិនិត្យមើលប្រព័ន្ធអគ្គិសនីដូចជា៖ បើកអំពូលភ្លើង ,កង្ហារ,កណ្តឹង និងឧឃោសនស័ព្ទ.ល.។

-រៀបចំ និង ត្រួតពិនិត្យអសនៈរបស់ចៅក្រមជំនុំជម្រះ(សម្រាប់រឿងទោល) ឬចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ(សម្រាប់រឿងក្រុមប្រឹក្សា) អសនៈរបស់តំណាងអយ្យការ ក្រឡាបញ្ជី មេធាវី កន្លែង

អង្គុយសម្រាប់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី អ្នកជំនាញ ជនជាប់ចោទ និងសាធារណៈជន ឬ អ្នកអង្កេតការណ៍ជាដើម ។

### ក. ការរៀបចំទុកដាក់វត្ថុតាង និងតុក្រចកសេះសម្រាប់ជនជាប់ចោទ

ការរៀបចំទុកដាក់ភស្តុតាង ក៏ជាតួនាទីរបស់ក្រឡាបញ្ជីសវនាការនៅមុនពេលចាប់ផ្តើមដំណើរការជំនុំជម្រះផងដែរ ។ ភស្តុតាងមួយចំនួនអាចត្រូវបានទុកដាក់នៅក្នុងបន្ទប់ជំនុំជម្រះដូចជា គ្រឿងញៀន ប្រាក់ ឬ ភស្តុតាង ដែលមិនបង្កអោយមានភាពអសន្តិសុខនៅពេលសវនាការ ប៉ុន្តែភស្តុតាងមួយចំនួនមិនអាចយកមកទុកនៅក្នុងបន្ទប់សវនាការបាននោះទេ ដូចជាៈ រថយន្ត ម៉ូតូ អាវុធ និងវត្ថុផ្សេងៗដែលងាយផ្ទុះជាដើម ព្រោះបន្ទប់សាលសវនាការអាចមានលក្ខណៈតូចចង្អៀត ហើយម្យ៉ាងទៀតវត្ថុតាងទាំងនោះវាងាយនឹងគ្រោះថ្នាក់ជាទីបំផុត ដូច្នេះវត្ថុតាងទាំងនោះគឺអាចយកមកបង្ហាញនៅក្នុងពេលសវនាការទេ បានត្រឹមតែយកមកធ្វើការពិនិត្យជារូបភាព រូបថត ឬ កំណត់ហេតុតែប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើតុលាការចង់ធ្វើការពិនិត្យនោះតុលាការអាចធ្វើការពិនិត្យបានដោយឆន្ទានុសិទ្ធិរបស់ខ្លួនទៅលើវត្ថុតាងជាក់ស្តែងបាន ។

ទន្ទឹមជាមួយគ្នានេះដែរ នៅពេលដែលមានដំណើរការនៃរឿងក្តីដែលជាប្រភេទរឿងក្តីរដ្ឋប្បវេណី មិនដែលមានការរៀបចំនូវតុក្រចកសេះសម្រាប់ភាគីនោះទេ ។ ប៉ុន្តែផ្ទុយទៅវិញសម្រាប់រឿងក្តីព្រហ្មទណ្ឌវិញក្រឡាបញ្ជីត្រូវធ្វើការរៀបចំនូវតុក្រចកសេះនេះជាចាំបាច់ ដែលជាកន្លែងសម្រាប់ជនជាប់ចោទឈរនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ ជាដើម ។

### ខ.ការរៀបចំបន្ទប់សម្រាប់ជនជាប់ចោទ និងសាក្សី

នៅតាមសាលាជម្រះក្តីនីមួយៗនៅក្នុងប្រទេសកម្ពុជា តែងតែមានបន្ទប់រង់ចាំសម្រាប់ជនជាប់ចោទ នៅពេលមានការបញ្ជូនមកកាន់សាលាដំបូង ។ មុនពេលសវនាការក្រឡាបញ្ជីត្រូវធ្វើការពិនិត្យ និងរៀបចំកន្លែងឲ្យជនជាប់ចោទឲ្យមានរបៀបរៀបរយ នៅក្នុងករណីដែលជនជាប់ចោទមានចំនួនច្រើននាក់ដែលធ្វើឲ្យចង្អៀតក្នុងបន្ទប់សាលសវនាការ ក្រឡាបញ្ជីត្រូវបង្គាប់ឲ្យមន្ត្រីពន្ធនាគារឲ្យនាំជនជាប់ចោទទៅអង្គុយរងចាំនៅក្នុងបន្ទប់រង់ចាំឲ្យបានត្រឹមត្រូវ ហើយត្រូវមានអ្នកការការពារនៅជាមួយផងដើម្បីចៀសវៀងការលួចរត់ ឬមានបញ្ហាអសន្តិសុខកើតឡើងជាដើម ។

ទន្ទឹមនឹងនេះដែរ ប្រសិនបើនៅក្នុងករណីជនរងគ្រោះជាអនីតិជនហើយបទល្មើសជាបទឧក្រិដ្ឋដែលមានលក្ខណៈធ្ងន់ធ្ងរ ឬអាចប៉ះពាល់ដល់កិត្តិយស ដូចជា បទល្មើសរំលោភសេពសន្ថវៈ បទល្មើសឃាតកម្ម ឬបទល្មើសផ្សេងៗទៀត ដែលធ្វើឲ្យអនីតិជនមានផលប៉ះពាល់ដល់សតិអារម្មណ៍ដូច្នេះក្រឡាបញ្ជីត្រូវធ្វើការរៀបចំបន្ទប់ផ្សេង ដើម្បីសម្រួលដល់អនីតិជនដែលធ្វើយ៉ាងណាឲ្យអនីតិជននោះ មានអារម្មណ៍ហ្នឹងហ្នរនៅក្នុងការឆ្លើយបំភ្លឺនៅក្នុងអំឡុងពេលសវនាការនោះ ។

បន្ថែមលើសពីនេះ នៅក្នុងបន្ទប់របស់អនីតិជននោះក៏ត្រូវបានបំពាក់នូវប្រព័ន្ធអេឡិចត្រូនិច ដែលអាចមើលឃើញរូបភាព និង សម្លេងស្តាប់លឺច្បាស់ដើម្បីងាយស្រួលក្នុងការប្រាស្រ័យទាក់ទងជាមួយចៅក្រម តំណាងអយ្យការ និងមេធាវីជាដើម ។ នៅក្នុងបន្ទប់របស់អនីតិជន ក៏អាចមានអាណាព្យាបាលរបស់អនីតិជននៅជាមួយផងដែរ ការធ្វើបែបនេះវាបានធ្វើអោយជនរងគ្រោះដែលជាអនីតិជនមានភាពក្លាហាន រឹងមាំ ក្នុងការឆ្លើយ នូវអ្វីដែលជាការពិត ។

ជាក់ស្តែងបច្ចុប្បន្ននៅសាលាដំបូងរាជធានីភ្នំពេញ បានបំពាក់នូវប្រព័ន្ធអេឡិចត្រូនិចនេះរួចរាល់ហើយ និងមានសាលាដំបូងមួយចំនួនក៏បានបំពាក់ហើយដែរ ដូចជា ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តព្រះសីហនុ ។

ចំពោះសាក្សីវិញនៅពេលចូលរួមសវនាការក្រឡាបញ្ជីត្រូវធ្វើការរៀបចំកន្លែងសម្រាប់សាក្សីអង្គុយនៅក្នុងបន្ទប់របស់សាក្សី ដោយមិនអនុញ្ញាតឲ្យសាក្សីអង្គុយស្តាប់នៅក្នុងអំឡុងពេលសវនាការដែលតុលាការកំពុងតែសួរចម្លើយជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះឡើយ ។ ការធ្វើបែបនេះ គឺក្នុងគោលបំណងមិនចង់អោយសាក្សីបានដឹង ឬ ឮនូវអ្វីដែលចៅក្រមបានសួរទៅលើជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ព្រោះខ្លាចសាក្សីឆ្លើយនូវអ្វីដែលខ្លួនមិនបានដឹង ឬមិនបានឮនៅពេលតុលាការសួរទៅលើខ្លួន ។ សាក្សីជាភស្តុតាងមួយ ក្នុងចំណោមភស្តុតាងដែលអាចឲ្យតុលាការមានការពិចារណាក្នុងការសម្រេចសេចក្តីរកបាននូវភាពយុត្តិធម៌ ។ កាលណាសាក្សីមានវត្តមាននៅក្នុងបន្ទប់សាលសវនាការ ដែលតុលាការបានសួរទៅភាគីទាំងសងខាងនោះ សាក្សីក៏អាចបានស្តាប់បានលឺនូវអ្វីដែលខ្លួនមិនបានដឹងហើយអាចឆ្លើយបំភ្លើសនូវអ្វីដែលខ្លួនបានដឹងបានឃើញ និងបានឮដែលធ្វើអោយតុលាការសម្រេចសេចក្តីមានភាពលក្ខណៈខុសពីការពិត[៦៧] ។

## កថាខណ្ឌទី២ ការធានាផ្នែកសន្តិសុខ

បញ្ហាសន្តិសុខជារឿងសំខាន់ ដែលតុលាការគប្បីត្រូវធ្វើការយកចិត្តទុកដាក់ដើម្បីជៀសវាងកុំឲ្យមានការកើតឡើងនូវបទល្មើសណាមួយជាយថាហេតុ ។ ដូច្នេះក្រឡាបញ្ជីក៏ត្រូវមានភារកិច្ចក្នុងការជួយរំលឹក និងអាចផ្តល់យោបល់ដល់ប្រធានសវនាការ ឬចៅក្រមជំនុំជម្រះផងដែរចំពោះករណីមួយចំនួនដែលជាប្រភេទរឿងក្តីធំៗជាដើម។

### ក.ពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកចូលរួម

នៅមុនពេលឲ្យភាគី ឬ សាធារណៈជនដែលមានបំណងចង់ចូលរួមនៅក្នុងការជំនុំជម្រះក្រឡាបញ្ជីត្រូវធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់នូវអត្តសញ្ញាណរបស់អ្នកចូលរួមទាំងនោះជាមុន

---

[៦៧] មាត្រា៣២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧

សិន ។ ការពិនិត្យគឺក្រឡាបញ្ជីត្រូវធ្វើការផ្ទៀងផ្ទាត់ឲ្យបានច្បាស់លាស់ត្រឹមត្រូវនូវអ្នកដែលត្រូវមានវត្តមាន ។ ចំពោះការចូលរួមនោះទៀតសោតអាចមានអង្គការសង្គមស៊ីវិល សាធារណៈជន និងបុគ្គលផ្សេងៗទៀត រួមទាំងមានប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀត ។ ប្រសិនបើមានករណីពិសេស ឬដោយមានភាពចាំបាច់ក្រឡាបញ្ជីត្រូវរាយការណ៍ជូនប្រធានសវនាការ ដើម្បីសុំការអនុញ្ញាតពីប្រធានសវនាការជាមុនសិន ។ ក្រឡាបញ្ជីគ្មានសិទ្ធិអនុញ្ញាតចំពោះការស្នើសុំណាមួយដែលអ្នកចូលរួម ឬគូភាគីបានស្នើសុំនោះឡើយ ។ រាល់ការអនុញ្ញាតក្រឡាបញ្ជីត្រូវតែសួរយោបល់ពីប្រធានសវនាការជាមុនដូចជា ៖ ការស្នើសុំតុលាការអំពីការថតរូប ការសុំថតសម្លេង ការអនុញ្ញាតឲ្យអ្នកកាសែតចូលរួម ឬ ប្រព័ន្ធឃោសនាផ្សេងៗជាដើម ។

ចំពោះភាគីក្រឡាបញ្ជីត្រូវហៅឈ្មោះ និង ផ្ទៀងផ្ទាត់អត្តសញ្ញាណនូវជនជាប់ចោទដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ។ កាលណាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានតំណាងដោយសហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់ ក្រឡាបញ្ជីត្រូវពិនិត្យអត្តសញ្ញាណអ្នកតំណាង និងពិនិត្យទៅលើសុពលភាពនៃលិខិតផ្ទេរសិទ្ធិនោះផងដែរ ។ ចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏ត្រូវធ្វើដូច្នេះដែរ [៥២] ។

### ខ. ត្រៀមរៀបចំលិខិតរដ្ឋបាលស្នើសុំកងកម្លាំងការពារ

ការត្រៀមរៀបចំលិខិតរដ្ឋបាល ស្នើសុំកងកម្លាំងការពារអាចធ្វើនៅមុនពេល ឬ បន្ទាប់ពីបានធ្វើការពិនិត្យ និង ផ្ទៀងផ្ទាត់ទៅលើអត្តសញ្ញាណរបស់ភាគីក៏ដូចជាអ្នកចូលរួម ប្រសិនបើយល់ឃើញថាមានភាពចាំបាច់ពាក់ព័ន្ធនឹងផ្នែកសន្តិសុខក្រឡាបញ្ជី ត្រូវផ្តល់យោបល់ដល់ប្រធានសវនាការអំពីភាពចាំបាច់នោះ និងស្នើសុំឲ្យប្រធានសវនាការធ្វើការសម្រេចរៀបចំលិខិតរដ្ឋបាល ដើម្បីសុំកងកម្លាំងការពារផ្នែកសន្តិសុខនៅក្នុងអំឡុងពេលដំណើរការសវនាការនោះក្នុងគោលបំណងដើម្បីបង្ការនឹងទប់ស្កាត់កុំឲ្យមានបទល្មើសកើតឡើងនៅពេលកំពុងធ្វើការជំនុំជម្រះនោះ។

ការត្រៀមរៀបចំលិខិតរដ្ឋបាលស្នើសុំកងកម្លាំងការពារ គឺជាការងារបន្ទាប់បន្សំរបស់ក្រឡាបញ្ជីដោយមិនមានបទបញ្ញត្តិណាមួយបានកំណត់ច្បាស់ថាជាការងារចាំបាច់របស់ក្រឡាបញ្ជីនោះឡើយ ។ ចំណុចនេះគឺគ្រាន់ជាការការពារមួយចំពោះការអនុវត្តការងារជាក់ស្តែងតែប៉ុណ្ណោះ ដោយហេតុថាកន្លងមកនេះ ក៏ធ្លាប់មានការកើតឡើងដោយស្មានមិនដល់ចំពោះសាលាដំបូងខេត្តបាត់ដំបង ដែលមានការរំដោះនូវជនជាប់ចោទក្នុងអំឡុងពេលដែលកំពុងដំណើរការសវនាការ ។

[៥២] មាត្រា៣២២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### គ. ការដឹកនាំធ្វើសម្បថ

ការធ្វើសម្បថគឺជាលក្ខណៈមួយដែលដាក់សំពាធទៅលើផ្នែកស្មារតី ក៏ដូចជាអារម្មណ៍របស់សាក្សីដើម្បីឲ្យសាក្សីនោះឆ្លើយទៅតាមការពិត និង ទៀងត្រង់នូវអ្វីដែលខ្លួនបានដឹង បានឮ និង បានឃើញ ។ ក្រឡាបញ្ជីត្រូវសួរសាក្សីដែលមានវត្តមានថានៅក្នុងដំណាក់កាលស៊ើបសួរ តើសាក្សីបានធ្វើសម្បថហើយ ឬ នៅ ? ប្រសិនបើសាក្សីបានឆ្លើយថានោះមិនបានស្បថនោះទេ ក្រឡាបញ្ជីត្រូវនាំសាក្សីនោះទៅស្បថនៅចំពោះមុខវត្ថុស័ក្កសិទ្ធិដែលមាននៅតាមសាលាដំបូងនីមួយៗ ដែលខ្លួនបានបំពេញការងារនោះ ។ ប្រសិនបើសាក្សីបានប្រាប់ថាខ្លួនបានធ្វើសម្បថរួចហើយ ក្រឡាបញ្ជីមិនបាច់ឲ្យសាក្សី ឬ អ្នកជំនាញទាំងនោះធ្វើសម្បថទៀតទេ ។

ប៉ុន្តែការធ្វើសម្បថត្រូវបានលើកលែង ប្រសិនបើសាក្សីនោះមានចូលនៅក្នុងលក្ខខ័ណ្ឌនៃមាត្រា **១៥៦** នៃក្រមព្រហ្មទណ្ឌ (សាក្សីដែលអនុញ្ញាតឲ្យរួចពីសម្បថ) ។

លើកលែងការធ្វើសម្បថចំពោះសាក្សីដែលបានរៀបរាប់ដូចខាងក្រោម ៖

១- ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនជាប់ចោទ

២- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនជាប់ចោទ

៣- បងប្អូន ប្រុស-ស្រី របស់ជនចាប់ចោទ

៤- បងប្អូនថ្លៃ ប្រុស-ស្រី របស់ជនជាប់ចោទ

៥- ប្តី ឬប្រពន្ធ របស់ជនជាប់ចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ

៦- កុមារអាយុតិចជាង ១៤ឆ្នាំ [៥៣] ។

ការធ្វើសម្បថ គឺក្រឡាបញ្ជីត្រូវឲ្យសាក្សីនោះស្បថទៅតាមសាសនា និង ជំនឿរបស់ខ្លួន ។ មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀនធូបបូជាចំពោះវត្ថុស័ក្កសិទ្ធិដែលខ្លួនស្បថនោះ។ បន្ទាប់មកក្រឡាបញ្ជីត្រូវអានប្រារព្ធវាទខ្លាំងៗច្បាស់ៗឲ្យអ្នកស្បថស្តាប់ រួចឲ្យសាក្សីអានពាក្យសច្ចាប្រណិធានតាមការអានរបស់ក្រឡាបញ្ជី ។ ក្រោយពីធ្វើសម្បថរួចក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឲ្យស្បថនោះបញ្ជាក់ថាបានធ្វើត្រឹមត្រូវ ហើយសេចក្តីវាចាឲ្យស្បថយ៉ាងណាត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង ។ កំណត់ហេតុនៃសម្បថនោះក្រឡាបញ្ជីត្រូវយកទៅដាក់ចូលនៅក្នុងសំណុំរឿងដែលនឹងត្រូវធ្វើការជំនុំជម្រះនោះ។

## ផ្នែកទី២ តួនាទីក្រឡាបញ្ជីក្នុងអំឡុងពេលប្រកាសបើកសវនាការ

នៅមុនពេលប្រកាសបើកសវនាការ ក្រឡាបញ្ជីត្រូវអានបទបញ្ជាផ្ទៃក្នុងរបស់សាលាដំបូងឲ្យបានយ៉ាងតិចពីរដង ដើម្បីឲ្យអ្នកចូលរួមទាំងអស់បានដឹង និងធ្វើការអនុវត្តតាម ព្រមទាំងប្រាប់ទៅសាធារណៈជនឲ្យក្រោកឈរពេលតុលាការចូលមកបន្ទប់សវនាការ។

---

[៥៣] មាត្រា៣២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

នៅពេលដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ បានចូលមកកាន់សាលសវនាការជំនុំជម្រះ ពេលនោះក្រឡាបញ្ជីត្រូវស្រែកឲ្យបានខ្លាំងៗថា **"តុលាការ"** បន្ទាប់មកអ្នកមានវត្តមាននៅក្នុងបន្ទប់សាលសវនាការទាំងអស់ត្រូវក្រោកឈរ ដើម្បីជាការគោរពរួចប្រធានក្រុមប្រឹក្សា ឬចៅក្រមជំនុំជម្រះអនុញ្ញាតឲ្យអង្គុយតាមកន្លែងរៀងៗខ្លួន និងប្រកាសបើកសវនាការ បន្ទាប់មកក្រឡាបញ្ជីត្រូវធ្វើការរាយការណ៍ពីវត្តមានអ្នកចូលរួម ។

**កថាខណ្ឌទី១.ពេលដំណើរការនីតិវិធីសវនាការ**

ពេលសវនាការចាប់ផ្តើមឡើង ក្រឡាបញ្ជីត្រូវបានបំពេញតួនាទីរបស់ខ្លួនជាអ្នកកត់ត្រាកំណត់ហេតុ និង ជាអ្នកអាននូវកំណត់ហេតុផ្សេងៗ ។ ដូច្នេះហើយបានអ្នកដែលធ្វើជាក្រឡាបញ្ជីត្រូវមានភាពឆ្លាតវៃ មានភាពប៉ិនប្រសព និងភាពរហ័សរហួន ទើបការងារមួយនេះមានល្អប្រសើរ ។

**ក. ការកត់ត្រានូវដំណើរការសវនាការ**

នៅពេលប្រកាសបើកសវនាការក្រឡាបញ្ជី ត្រូវផ្ចង់អារម្មណ៍ឲ្យបានល្អដោយត្រៀមលក្ខណៈក្នុងការកត់ត្រារាល់សេចក្តីដែលសួរដេញដោល និងសកម្មភាពដែលបានកើតឡើងនាពេលសវនាការ ។ ក្រឡាបញ្ជីត្រូវធ្វើការកត់ត្រារាល់សំនួររបស់ចៅក្រមជំនុំជម្រះ និងព្រះរាជអាជ្ញា មេធាវី ដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទ និងសាក្សី ទាំងការសួរនឹងការឆ្លើយនៅក្នុងសវនាការនោះតែម្តង ។ រាល់សកម្មភាពដែលបានកើតឡើងក្នុងពេលសវនាការនោះ ក្រឡាបញ្ជីត្រូវកត់ត្រាដាក់នៅក្នុង **"សៀវភៅកំណត់ហេតុស្តីពីការជំនុំជម្រះផ្នែកព្រហ្មទណ្ឌ"** ។

កំណត់ហេតុជំនុំជម្រះត្រូវសរសេរនៅក្នុងសៀវភៅលាតធម្មតាមួយ ហើយកំណត់ហេតុជំនុំជម្រះនេះមានសារៈសំខាន់ណាស់ព្រោះថាតុលាការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាងដែលបានពីលទ្ធផលនៃពិភាក្សាដេញដោល ។ ភស្តុតាងខ្លះវាមាននៅក្នុងសំណុំរឿងស្រាប់តែភស្តុតាងមួយចំនួនវាបានកើតឡើងថ្មីមាននាពេលសវនាការ ឬមួយចំនួនទៀតជាភស្តុតាងដែលមានអានុភាពច្រានចោលភស្តុតាងដែលមាននៅក្នុងដំណាក់កាលអយ្យការ ឬ ដំណាក់កាលស៊ើបសួរ ដូច្នេះកំណត់ហេតុនេះត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់នូវព្រឹត្តការណ៍ដែលបានកើតឡើងដែលបញ្ជាក់អំពីភស្តុតាង ។ ភស្តុតាងត្រូវទុកជាឯកសារបន្ទាល់នូវខ្លឹមសារដែលត្រូវជឿជាក់រហូតមានភស្តុតាងផ្ទុយ ។

កាលណាមានសេចក្តីសម្រេចមិនស្របគ្នារវាងកំណត់ហេតុ និងសាលក្រម នោះសាលក្រមដើមនឹងទុកជាបានការ ។ កំណត់ហេតុសវនាការមានសារៈសំខាន់ណាស់ ព្រោះវាមានគោលដៅមួយជា មធ្យោបាយមួយដល់សាលាឧទ្ធរណ៍ក្នុងការពិនិត្យនីត្យានុកូលនៃនីតិវិធី និងបានយល់ដឹងអំពីកិច្ចពិភាក្សាដេញដោលរបស់សាលាដំបូង មុននឹងសាលាឧទ្ធរណ៍សម្រេចសេចក្តីថាត្រូវបដិសេធ

ឬ តម្កល់ទុកសាលក្រមរបស់សាលាដំបូងទុកជាបានការ ។ ក្រឡាបញ្ជីត្រូវខិតខំសរសេរដោយយកចិត្តទុកដាក់អំពីការប្រព្រឹត្តទៅនៃសវនាការ និងកត់ត្រាឲ្យបានត្រឹមត្រូវតាមសំណួរដែលសួរព្រមទាំងចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ។ កំណត់ហេតុសវនាការត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុង រយៈពេល១០ថ្ងៃក្រោយថ្ងៃប្រកាសសាលក្រម ។ ប្រសិន បើក្រឡាបញ្ជីណាម្នាក់ខ្ជីខ្ជានៅក្នុងការកាន់កាប់កំណត់ហេតុសវនាការ ត្រូវទទួលទណ្ឌកម្មខាងវិន័យ[៥៥] ។

**ខ.ការអានឡើងវិញកំណត់ហេតុសវនាការ**

នៅពេលសវនាការ ក្រៅពីតួនាទីក្នុងការកត់ត្រានូវកំណត់ហេតុក្រឡាបញ្ជីនៅមានតួនាទីជាអ្នកអាននូវកំណត់ហេតុមួយចំនួនតាមការបញ្ជារបស់ប្រធានសវនាការ ។ នៅពេលសួរចម្លើយជនជាប់ចោទ ក្នុងករណីជនជាប់ចោទមានការភ្លេច ឬបដិសេធនូវចម្លើយទាំងនោះ ប្រធានសវនាការអាចបញ្ជាឲ្យក្រឡាបញ្ជីអាននូវកំណត់ហេតុ ។ កំណត់ហេតុទាំងនេះអាចជាកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី កំណត់ហេតុសួរចម្លើយជនជាប់ចោទ ដែលមាននៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់ការចៅក្រមស៊ើបសួរ ។ ក្រឡាបញ្ជីត្រូវអានកំណត់ហេតុឲ្យបានខ្លាំងៗ ដើម្បីឲ្យជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីបានឮនូវចម្លើយដែលខ្លួនបានឆ្លើយពីមុន ។

**កថាខណ្ឌទី៣ ការប្រកាសសេចក្តីសម្រេច**

ក្រោយពីការកិច្ចពិភាក្សាដេញដោលត្រូវបានបញ្ចប់ តុលាការត្រូវធ្វើការប្រកាសសេចក្តីសម្រេច ប៉ុន្តែមុននឹងប្រកាសសេចក្តីសម្រេចតុលាការក៏ត្រូវការពេលវេលាខ្លះសម្រាប់ធ្វើការពិចារណាផងដែរ ។

**ក.ការថយទៅពិភាក្សា**

តុលាការ (ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ) ថយខ្លួនចូលទៅបន្ទប់ពិភាក្សានៅតាមសាលសវនាការនីមួយៗ ដើម្បីសម្រេចសេចក្តីលើរឿងដែលខ្លួនបានជំនុំជម្រះនោះ ។ ការប្រកាសថយទៅពិភាក្សាគឺប្រើសម្រាប់ការជំនុំជម្រះក្តីជាក្រុមប្រឹក្សា ករណីដែលការជំនុំជម្រះក្តីដោយចៅក្រមទោល គឺគេប្រើពាក្យថាជាការថយទៅពិចារណា ។ ព្រះរាជអាជ្ញា និងក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងបន្ទប់នៃការពិភាក្សាសម្រេចនោះទេ ប៉ុន្តែក្រឡាបញ្ជីត្រូវរក្សាសណ្តាប់ធ្នាប់នៅក្នុងបន្ទប់សវនាការប្រាប់ភាគីទាំងអស់ឲ្យនៅរងចាំ និង ឲ្យក្រោយឈរដើម្បីស្តាប់ការប្រកាសសាលក្រមនៅពេលប្រធានសវនាការចេញមកបន្ទប់សវនាការវិញដើម្បីប្រកាសសាលក្រម ។

[៥៥] មាត្រា ៣៩១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

**ខ.ការប្រកាសសាលក្រម**

ក្រោយពីបានធ្វើការពិភាក្សា ឬធ្វើការពិចារណារួចហើយ តុលាការត្រូវចូលមកកាន់បន្ទប់សវនាការវិញដើម្បីប្រកាសសេចក្តីសម្រេចជាសាធារណៈ ។ ពេលចៅក្រមចូលមកក្នុងបន្ទប់សាលសវនាការវិញ ក្រឡាបញ្ជីត្រូវប្រាប់ឲ្យអ្នកនៅក្នុងបន្ទប់សាលសវនាការក្រោកឈរឡើង ចាំស្តាប់អំពីការប្រកាសសាលក្រម ។ ផ្នែកនៃសេចក្តីសម្រេចត្រូវអានឲ្យខ្លាំងៗដោយប្រធានសវនាការ ឬ ប្រសិនបើការប្រកាសសាលក្រមនោះត្រូវធ្វើនៅថ្ងៃក្រោយនោះ ប្រធានសវនាការត្រូវជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាននៅទីនោះអំពីថ្ងៃដែលត្រូវប្រកាសសាលក្រម [៥៥] ។

ដូច្នេះ នៅពេលលើកថ្ងៃសវនាការ ក្រឡាបញ្ជីត្រូវជូនដំណឹងដល់ភាគីដែលអវត្តមាននោះឲ្យមកស្តាប់ការប្រកាសសាលក្រមតាមកាលបរិច្ឆេទដូចដែលប្រធានសវកាការបានសម្រេច ។ នៅថ្ងៃប្រកាសសាលក្រមក្រឡាបញ្ជី ត្រូវមានវត្តមាននៅក្នុងសាលសវនាការ ហើយធ្វើការកត់ត្រានូវអ្វីដែលប្រធានក្រុមប្រឹក្សា ឬចៅក្រមជំនុំជម្រះបានប្រកាសនូវលើកំណត់ហេតុប្រកាសសាលក្រម ។

[៥៥] មាត្រា ៣៩៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ជំពូកទី៣
# តួនាទីក្រឡាបញ្ជីក្រោយដំណាក់កាលក្រោយសវនាការ

បន្ទាប់ពីប្រធានសវនាការបានប្រកាសបិទសវនាការក្រឡាបញ្ជីត្រូវរៀបចំទុកដាក់សំណុំរឿង និងវត្ថុតាងដែលត្រូវយកមកបង្ហាញនៅពេលដំណើរការសវនាការនោះ ។ ករណីខ្លះប្រសិនបើអាចឲ្យភាគី ឬ សាក្សីផ្តិតមេដៃឬមេធាវីការពារក្តីចុះហត្ថលេខាបានកាន់តែប្រសើរ ដើម្បីបញ្ជាក់អំពីវត្តមានដែលបានចូលរួម និងទុកជាភស្តុតាងបញ្ជាក់ថាភាគី ឬ សាក្សីនោះពិតជាបានឆ្លើយដូចដែលក្រឡាបញ្ជីបានកត់ត្រាពិតប្រាកដមែន ។

នៅក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងរាជធានីភ្នំពេញ យើងបានសង្កេតឃើញថាក្រោយពីចៅក្រមបានបានប្រកាសថាបិទសវនាការ ហើយប្រកាសសាលក្រមនៅថ្ងៃនោះ ឬ លើកការប្រកាស ក្រឡាបញ្ជីតែងតែបានឲ្យភាគីផ្តិតមេដៃទទួលស្គាល់អំពីវត្តមានរបស់ខ្លួន ជាពិសេសនោះគឺជនត្រូវចោទតែម្តង ។

ទន្ទឹមនឹងគ្នានេះដែរ ប្រសិនបើមានសំណួរដែលគូភាគីបានសួរព្រោះតែពួកគាត់ស្តាប់មិនបានច្បាស់ ឬមិនយល់ត្រង់ចំណុចណានោះដែលតុលាការបានសម្រេច និងបានប្រាប់អំពីសិទ្ធិប្តឹងទាស់ ឬ ឧទ្ធរណ៍ចំពោះសាលក្រមនោះក្រឡាបញ្ជីត្រូវឆ្លើយនឹងសំណួរទាំងនោះ ។ មិនតែប៉ុណ្ណោះមុននឹងចាកចេញពីបន្ទប់សវនាការក្រឡាបញ្ជីត្រូវបិទនូវឧបករណ៍ផ្សេងៗដូចជា ឧឃោសនស័ព្ទ ភ្លើង កង្ហារ កណ្តឹង ម៉ាស៊ីនត្រជាក់ ទ្វារ សវនាការផង ។

ក្រៅពីកិច្ចការដែលបានបញ្ចប់ក្រោយពីសវនាការដូចបានរៀបរាប់ខាងលើ ក្រឡាបញ្ជីនៅមិនទាន់អស់ភារកិច្ចនៅឡើយទេ ។ ខាងក្រោមនេះជាភារកិច្ចដែលក្រឡាបញ្ជីត្រូវធ្វើបន្តទៀត ។

## ផ្នែកទី១ ការព្រាងឯកសារដែលទាក់ទងសាលក្រម និងការជូនដំណឹង

### កថាខណ្ឌទី១ ប្រភេទឯកសារដែលត្រូវព្រាង

នៅពេលសាលក្រមត្រូវបានប្រកាសរួចហើយ ក្រឡាបញ្ជីត្រូវធ្វើការព្រាងនូវឯកសារមួយចំនួនដែលមានការទាក់ទងជាមួយសាលក្រមដែលក្នុងនោះមាន៖ ដីកាចាប់-ឃុំខ្លួនតាមសាលក្រម (៣៥៣) ,សម្រង់សាលក្រម ,លិខិតជូនដំណឹងអំពីសាលក្រម និងសាលក្រម ។

**ក.ដីកាចាប់-ឃុំខ្លួនតាមសាលក្រម**(**តាម៣៥៣**)

ប្រសិនបើតុលាការបានប្រកាសសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ១ឆ្នាំ យ៉ាងតិចដោយគ្មានការព្យួរទេនោះ តុលាការអាចសេចក្តីសម្រេចពិសេស និងមានសំអាងហេតុតុលាការអាចចេញដីកានៅពេលសវនាការបានដូចជា [៦] ៖

- ដីកាបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាននៅក្នុងសវនាការ

[៦] ឧសម្ព័ន្ធទី១៦ ដីកាបង្គាប់ឲ្យចាប់ និងឃុំខ្លួន

- ដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទដែលអវត្តមាន ។

ដីកាបង្គាប់ឲ្យឃុំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួន មានអនុភាពអនុវត្តភ្លាម ។ ក្រឡាបញ្ជីត្រូវធ្វើការព្រាងដីកាទាំងនេះ ហើយយកទៅជូនចៅក្រមដើម្បីចុះហត្ថលេខានិងធ្វើការបោះត្រារួចធ្វើការបញ្ជូនទៅលេខាធិការដ្ឋានផ្នែកព្រហ្មទណ្ឌ ដើម្បីលេខាធិការដ្ឋានបញ្ជូនទៅដល់មន្ត្រីនគរបាលយុត្តិធម៌អនុវត្តដីកានេះតាមអំណាចរបស់ខ្លួន។

ដីកាទាំងនោះមានចុះនិទ្ទេសដូចតទៅ៖

- អត្តសញ្ញាណរបស់ពិរុទ្ធជន
- ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ដែលជាមូលដ្ឋាននៃការផ្តន្ទាទោសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកានោះត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រម និង មានការបោះត្រាផង ។ ពិរុទ្ធជនដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឲ្យចាប់ខ្លួននោះ ត្រូវបានគេនាំទៅបង្ហាញខ្លួនយ៉ាងខ្លីបំផុតនៅមុខព្រះរាជអាជ្ញានាទីកន្លែងដែលចាប់ខ្លួនដែលឲ្យដំណឹងដល់សាមីខ្លួនអំពីដីកានេះ និងធ្វើការឃុំខ្លួនតែម្តង [៤៧] ។

**ខ.សម្រង់សាលក្រម**

សម្រង់សាលក្រមជាលិខិតមួយដែលចេញដោយចៅក្រមជំនុំជម្រះ តាមបែបបទរដ្ឋបាលតុលាការក្នុងការជូនដំណឹងអំពីសាលក្រមដល់មន្ត្រីពន្ធនាគារ ។ សម្រង់សាលក្រម វាហាក់ដូចជាសាលក្រមដែរ តែវាមានទម្រង់ខ្លីជាងសាលក្រមបន្តិច ។ ច្បាប់មិនបានកំណត់អំពីការធ្វើសម្រង់សាលក្រមនោះទេ តែដោយសារតែការធ្វើសាលក្រមមានលក្ខណៈយឺតបន្តិច ដូច្នេះរដ្ឋបាលតុលាការបានសម្រេចឲ្យធ្វើសម្រង់សាលក្រមជំនួសសាលក្រមជាបណ្តោះអាសន្នសិន ។

នៅក្នុងសម្រង់សាលក្រមមានចុះនិទ្ទេសដូចតទៅ៖

- ឈ្មោះចៅក្រមជំនុំជម្រះ
- លេខសំណុំរឿង និងលេខសាលក្រម
- អត្តសញ្ញាណពិរុទ្ធជន
- បទចោទប្រកាន់លើពិរុទ្ធជន
- សេចក្តីសម្រេចរបស់តុលាការ

[៤៧] មាត្រា ៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និង

នៅក្នុងសម្រង់សាលក្រមត្រូវមានចុះហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមជំនុំជម្រះ ហត្ថលេខាតំណាងអយ្យការ និងហត្ថលេខារបស់ក្រឡាបញ្ជី [៥៨] ។

សម្រង់សាលក្រមត្រូវធ្វើជាបីច្បាប់ ដែលមួយច្បាប់ក្រឡាបញ្ជីរក្សាទុកនៅក្នុងសំណុំរឿងមួយច្បាប់ទៀតទុកនៅតំណាងអយ្យការ និងមួយច្បាប់ទៀតបញ្ជូនទៅប្រធានពន្ធនាគារ ។

**គ.សាលក្រម**

សាលក្រម គឺជាសេចក្តីសម្រេចចុងក្រោយជាលាយល័ក្ខណ៍អក្សររបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូង ដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលកំណត់ដោយច្បាប់បន្ទាប់ពីឆ្លងកាត់ដំណើរនៃកិច្ចពិភាក្សាដេញដោលនៅក្នុងនីតិវិធីសវនាការ ។

ការតាក់តែងសាលក្រមជាសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ តែដោយសារក្រឡាបញ្ជីជាសេនាធិការរបស់ចៅក្រម ដូច្នេះសាលក្រមត្រូវពង្រាងដោយរបស់ក្រឡាបញ្ជី ។ ការសរសេរសាលក្រមគ្រាន់តែជាការសេចក្តីព្រាងតែប៉ុណ្ណោះ ចំណែកឯត្រង់សេចក្តីសម្រេចយ៉ាងណានោះ គឺជាការសម្រេចរបស់ចៅក្រម ។

នៅក្នុងការព្រាងសាលក្រម ក្រឡាបញ្ជីត្រូវយល់ដឹងអំពីរបៀបសរសេរ គឺយល់ដឹងអំពីលក្ខខណ្ឌទម្រង់ ឬលក្ខខណ្ឌជារូបមន្ត និងលក្ខខណ្ឌខ្លឹមសារ ឬលក្ខខណ្ឌជាសារធាតុ [៥៩] ។

**១).លក្ខខណ្ឌទម្រង់ ឬលក្ខខណ្ឌជារូបមន្តនៅក្នុងសាលក្រម**

ដោយយោងតាមមាត្រា **៣៥៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាលក្ខខណ្ឌជារូបមន្តសាលក្រមត្រូវចុះហត្ថលេខាដោយចៅក្រម និងក្រឡាបញ្ជី ដោយមានបោះត្រាផង ។ នៅក្នុងសាលក្រមត្រូវចុះនិទ្ទេសដូចខាងក្រោម ៖

- កាលបរិច្ឆេទនៃសវនាការ
- កាលបរិច្ឆេទនៃការប្រកាសសាលក្រម
- ឈ្មោះ និងឋានៈរបស់ចៅក្រមជំនុំជម្រះ
- ឈ្មោះ និងឋានៈរបស់តំណាងអយ្យការ
- ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី
- ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជានជាប់ចោទរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

---

[៥៨] ឧសម្ព័ន្ធទី១៧ សម្រង់អំពីសាលក្រម

[៥៩] ឧសម្ព័ន្ធទី២០ ដីកាបង្គាប់ឲ្យចាប់ និងឃុំខ្លួន

- ឈ្មោះរបស់មេធាវី ។

**២).លក្ខខណ្ឌខ្លឹមសារ ឬលក្ខខណ្ឌជាសារធាតុ**

បើផ្អែកតាមមាត្រា **៣៥៧** ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការសរសេរសាលក្រមត្រូវកំណត់ជាពីរផ្នែកគឺ ផ្នែកសំអាងហេតុ និងផ្នែកសម្រេចចេញសេចក្តីសម្រេច ។

ផ្នែកសំអាងហេតុ: គឺសរសេរអំពីទទ្បីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឲ្យតុលាការចេញសេចក្តីសម្រេច ។

ផ្នែកសម្រេចសេចក្តី គឺជាសេចក្តីសម្រេចរបស់តុលាការ ។

អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗនិងទទ្បីករណ៍ដែលបានលើកនៅពេលសវនាការ ។ នៅក្នុងសំអាងហេតុតុលាការត្រូវឆ្លើយតបទៅនិងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី ។ ផ្នែកសម្រេចសេចក្តីត្រូវចុះនិទ្ទេសអំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុស អត្ថបទច្បាប់ដែលអនុវត្តទោស និង ទណ្ឌកម្មរដ្ឋប្បវេណី ។

## កថាខណ្ឌទី២ ការជូនដំណឹងអំពីសាលក្រម [៥០]

ក្រោយពីបានធ្វើការសម្រេចសេចក្តីហើយ សេចក្តីសម្រេចនោះត្រូវជូនដំណឹងទៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមលក្ខណ្ឌដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។ ការជូនដំណឹងនេះក្រឡាបញ្ជីត្រូវដឹងថាប្រភេទសាលក្រមអ្វីខ្លះដែលត្រូវជូនដំណឹង ហើយសាលក្រមអ្វីខ្លះដែលមិនត្រូវជូនដំណឹង ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌសាលក្រមត្រូវបានបែងចែកជាបីគឺ សាលក្រមចំពោះមុខ សាលក្រមចាត់ទុកចំពោះមុខ និងសាលក្រមកំបាំងមុខ ។

**ក.សាលក្រមចំពោះមុខ**

កាលណាជនជាប់ចោទបានបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រមនោះជាសាលក្រមចំពោះមុខ ។ ទោះបីជាជនជាប់ចោទបានចាកចេញពីបន្ទប់សវនាការក៏ដោយក៏នៅតែជាសាលក្រមចំពោះមុខដែរ ។ ម្យ៉ាងទៀតក៏នៅចាត់ទុកជាសាលក្រមចំពោះមុខដែរ ប្រសិនបើមូលហេតុស្ថានភាពសុខភាព ឬដោយមូលហេតុធ្ងន់ធ្ងរ ដែលធ្វើឲ្យជនជាប់ចោទមិនអាចចូលបង្ហាញខ្លួនបាននៅចំពោះមុខតុលាការ ហើយប្រធានតុលាការអាចបង្គាប់ឲ្យសួរចម្លើយជនជាប់ចោទនៅទីកន្លែងដែលជននោះរស់នៅ ។

[៥០] ឧបសម្ព័ន្ធទី ១៩ លិខិតជូនដំណឹងអំពីសាលក្រមកំបាំងមុខ

ក្រៅពីជនជាប់ចោទ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីបានចូលបង្ហាញខ្លួននៅពេលសវនាការ ឬមានអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនេះត្រូវតែជាសាលក្រមចំពោះមុខដែលគេហៅថា សាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។

សាលក្រមចំពោះមុននោះមិនត្រូវឲ្យជូនដំណឹងទៅជនជាប់ចោទ ដើបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីនោះទេ [៥១] ។

**ខ.សាលក្រមចាត់ទុកចំពោះមុខ**

សាលក្រមចាត់ទុកថាជាចំពោះមុខ គឺជាការមិនចូលមកបង្ហាញខ្លួននៅពេលសវនាការ ប៉ុន្តែសាមីខ្លួនបានដឹងអំពីការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅហើយនោះ ប៉ុន្តែនៅតែមិនចូលមកបង្ហាញខ្លួនទៀត ត្រូវបានគេចាត់ទុកថាជាសាលក្រមចាត់ទុកថាចំពោះមុខ ។ សាលក្រមចាត់ទុកថាចំពោះមុខនេះ តុលាការត្រូវធ្វើការជូនដំណឹងស្តីពីសាលក្រមដល់ជនជាប់ចោទ ។

នៅក្នុងករណីដែលជនជាប់ចោទអវត្តមាន បានបង្ហាញមូលហេតុអំពីការអវត្តមានរបស់ខ្លួន ហើយតុលាការក៏បានទទួលស្គាល់ថាត្រឹមត្រូវ នោះតុលាការអាចលើករឿងទៅជំនុំជម្រះនៅសវនាការមួយក្រោយទៀត [៥២] ។

**គ.សាលក្រមកំបាំងមុខ**

សាលក្រមកំបាំងមុខ ជាសាលក្រមទាំងឡាយណាដែលជនជាប់ចោទមិនបានបង្ហាញខ្លួននៅពេលសវនាការទេ ហើយនឹងប្រសិនបើឃើញថាគ្មានភស្តុតាងណាបង្ហាញឲ្យឃើញថាសាមីខ្លួនដឹងអំពីការជំនុំជម្រះ ឬមិនបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវបានប្រកាសថាជាសាលក្រមកំបាំងមុខ ។

ម្យ៉ាងទៀតប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនបានចូលបង្ហាញខ្លួននៅពេលសវនាការ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមត្រូវបានសម្រេចដោយសាលក្រមកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

សាលក្រមប្រភេទនេះត្រូវជូនដំណឹងទៅជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី [៥៣] ។

---

[៥១] មាត្រា ៣៦០,៣០៩,៣៦៣ និងមាត្រា៣៦៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៥២] មាត្រា៣៦១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៥៣] មាត្រា ៣៦២,៣៦៣ និងមាត្រា៣៦៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

## ផ្នែកទី២ តួនាទីក្នុងការទទួលបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងដែលទាក់ទងទៅនឹងសេចក្តីសម្រេចរបស់តុលាការវាអាចជាបណ្តឹងទៅតុលាការជាន់ទាបដដែល ឬ អាចប្តឹងទៅតុលាការជាន់ខ្ពស់ ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌក្រោយពីប្រធានសវនាការបានប្រកាសសាលក្រមរួចតែងតែទុកសិទ្ធិឲ្យគូភាគីក្នុងការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ។

### កថាខណ្ឌទី១ ប្រភេទនៃបណ្តឹងឧបាស្រ័យ

ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌតាំងពីដើមរហូតដល់ចប់ជាស្ថាពរក្នុងកិច្ចនៃនីតិវិធី តុលាការបានសម្រេចដោយដីកាសម្រេចជាច្រើនករណីប្លែកៗគ្នា មុននឹងសម្រេចថាចេញសាលក្រមចុងក្រោយ ។ ប្រសិនបើគូភាគីមិនពេញចិត្តទៅនឹងសាលក្រមចុងក្រោយនោះ ដោយយល់ឃើញថាការសម្រេចនោះវាធ្វើឲ្យបាត់បង់ប្រយោជន៍របស់ខ្លួន ឬពិរុទ្ធជនយល់ឃើញថាការសម្រេចផ្តន្ទាទោសមកលើខ្លួនវាមិនសមស្របទៅនឹងអំពើដែលខ្លួនបានប្រព្រឹត្តនោះភាគីអាចមានសិទ្ធិធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍បានទៅតាមការកំណត់របស់ច្បាប់ ។

#### ក.បណ្តឹងទាស់

បណ្តឹងទាស់អាចធ្វើប្រឆាំងនឹងសាលក្រមកំបាំងមុខមានន័យថានៅពេលដែលជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនបានបង្ហាញខ្លួននៅពេលសវនាការ និងបានបង្ហាញថាខ្លួនបានដឹងអំពីការកោះហៅ នោះសាលក្រមនិងបើកផ្លូវឲ្យធ្វើបណ្តឹងទាស់ [54] ។ បណ្តឹងទាស់ ត្រូវធ្វើដោយពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬ នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ឬ នៅចំពោះមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន [៥៥] ។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ប៉ុន្តែមេធាវីត្រូវតែមានលិខិតអនុញ្ញាតឲ្យធ្វើបណ្តឹងទាស់ ។ ពិរុទ្ធជនអាចត្រូវតំណាងដោយឪពុកម្តាយ ឬ អ្នកអាណាព្យាបាលក៏បាន ។ ក្នុងករណីនេះ អ្នកតំណាងឲ្យពិរុទ្ធជនមិនចាំបាច់មានលិខិតអនុញ្ញាតទេ ។

បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ថ្ងៃ ដោយផ្តើមគិតពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ដល់ពិរុទ្ធជនដោយផ្ទាល់ដៃ ឬ គិតចាប់ពីថ្ងៃដែលពិរុទ្ធជន

[៥៤] មាត្រា ៣៦៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៥៥] មាត្រា ៣៦៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

នេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃទេ [៥៦] ។

**ខ.បណ្តឹងឧទ្ធរណ៍**

បណ្តឹងឧទ្ធរណ៍ ជាការជំទាស់ទៅនឹងសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងទៅកាន់តុលាការឧទ្ធរណ៍ ។

បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បានមានៈ

- ព្រះរាជអាជ្ញាអមសាលាដំបូង ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ពិរុទ្ធជន [៥៧]
- ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។ ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី តែត្រូវមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែចំពោះពិរុទ្ធជនដែលជាអនីតិជន អាចតំណាងដោយឪពុកម្តាយ ឬអាណាព្យាបាល ។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍នោះទេ ។

ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតបាន។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍ [៥៨] ។

ចំពោះពិរុទ្ធជនដែលកំពុងជាប់ឃុំនៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន អាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍នៅមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដោយបំពេញពាក្យបណ្តឹងឧទ្ធរណ៍នេះដែលត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។ ពាក្យប្តឹងឧទ្ធរណ៍ត្រូវចុះបញ្ជីដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួននៅលើបញ្ជីពិសេស ហើយឲ្យពិរុទ្ធជនចុះហត្ថលេខានៅរឹមនៃទំព័របញ្ជីនេះ ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវបញ្ជូនពាក្យបណ្តឹងក្នុងរយៈពេលខ្លីបំផុតទៅក្រឡាបញ្ជីនៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យបណ្តឹងឧទ្ធរណ៍នេះ នៅលើបញ្ជីបណ្តឹងឧទ្ធរណ៍នៃតុលាការ ។

---

[៥៦] មាត្រា ៣៦៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៥៧] ឧបសម្ព័ន្ធទី ២០ ពាក្យបណ្តឹងឧទ្ធរណ៍

[៥៨] មាត្រា ៣៧៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ចំពោះការប្តឹងរបស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ។ ក្រឡាបញ្ជីចុះលិខិតប្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យនៃសាលាឧទ្ធរណ៍ ។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា ។

នៅក្នុងការប្តឹងឧទ្ធរណ៍ ក្រមនីតិវិធីព្រហ្មទណ្ឌបានទុករយៈពេលដូចខាងក្រោម៖

- សម្រាប់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ការប្តឹងឧទ្ធរណ៍ត្រូវធ្វើក្នុងរយៈពេល១(មួយ)ខែ ។
- ការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល១(មួយ)ខែ
- ការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល៣(មួយ)ខែ [៥៩] ។

ក្នុងករណីពិសេស នៅក្នុងរឿងឃុំខ្លួន ការប្តឹងឧទ្ធរណ៍ត្រូងធ្វើដោយព្រះរាជាអាជ្ញានៅក្នុងរយៈពេល៤៨ម៉ោង និងដោយពិរុទ្ធជនក្នុងរយៈពេល៥ថ្ងៃ ដែលរយៈពេលនេះគិតចាប់ពីថ្ងៃដែលតុលាការសម្រេចឃុំខ្លួន [៦០] ។

## កថាខណ្ឌទី២ អនុភាពនៃបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍

### ក.អានុភាពនៃបណ្តឹងទាស់

នីតិវិធីនៃបណ្តឹងទាស់ មានអនុភាពព្យួរដែលបន្តពីអានុភាពរំលត់ ។ បណ្តឹងទាស់អនុញ្ញាតឲ្យទុកជាសូន្យនូវសេចក្តីសម្រេច និងការព្យួរការអានុភាពសេចក្តីសម្រេចនោះ ។ ប៉ុន្តែដីកាបង្គាប់ឲ្យចាប់ខ្លួននៅតែបន្តមានអានុភាព ។ តុលាការនៅតែមានសមត្ថកិច្ចដើម្បីសម្រេចអំពីការដោះលែងជនជាប់ចោទឲ្យមានសេរីភាពវិញ ។

កាលណាបណ្តឹងទាស់ធ្វើឡើងប្រឆាំងទៅនឹងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី មានតែសេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះដែលទុកជាអសារបង់ ។ រាល់ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនេះត្រូវព្យួរ។ អានុភាពរំលត់នៃសេចក្តីសម្រេចមានគោលដៅអនុញ្ញាតឲ្យតុលាការដែលវិនិច្ឆ័យលើបណ្តឹងទាស់អាចប្តឹងមកខ្លួនឯងបាននូវរឿងក្តីទាំងមូល ឬ ត្រឹមតែចំណុចដែលពាក់ព័ន្ធនឹងបណ្តឹងទាស់ ។

សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះនៅចំពោះមុខតុលាការដដែល ។ បើអ្នកប្តឹងទាស់ចូលមកបង្ហាញខ្លួនយ៉ាងពិតប្រាកដនៅសវនាការ អំណាចរបស់តុលាការមិនត្រូវបានកំណត់ក្នុងគ្រប់វិស័យ(បណ្តឹងអាជ្ញា ឬបណ្តឹងរដ្ឋប្បវេណី) និងក្នុងគ្រប់អត្ថន័យ ។ បណ្តឹងទាស់អាចបន្ថយ ឬតំ

[៥៩] មាត្រា ៣៨១ និងមាត្រា ៣៨២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៦០] មាត្រា ៣៨៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ឡើងការផ្តន្ទាសទោស ។ ប៉ុន្តែប្រសិនបើអ្នកប្តឹងទាស់មិនបានបង្ហាញខ្លួននៅសវនាការ តុលាការអាចប្រកាសបណ្តឹងទាស់ទុកជាអសារឥតការ [៦១] ។

### ខ.អានុភាពនៃបណ្តឹងឧទ្ធរណ៍

នៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបានបង្អង់សិនប៉ុន្តែជនជាប់ចោទដែលត្រូវបានជាប់ឃុំដែលបានចូលបង្ហាញខ្លួន នៅចំពោះមុខតុលាការជាន់ដំបូងត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច ។ ក្នុងករណីដែលតុលាការជាន់ដំបូងបានសម្រេចឲ្យរួចខ្លួន ឬ បានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង ឬ ស្មើនឹង រយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឲ្យមានសេរីភាពមុនពេលផុតកំណត់ នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍ ។ រយៈពេលប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ [៦២] ។

នៅក្នុងករណីដែលសាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍ពីជនជាប់ចោទតែម្នាក់ប៉ុណ្ណោះ នោះសាលាឧទ្ធរណ៍មិនអាចដាក់ទម្ងន់ទោសដល់ជននោះបានទេ ។ តុលាការអាចកែប្រែសាលក្រមបានក្នុងន័យដែលអនុគ្រោះដល់ជននេះតែប៉ុណ្ណោះ ។ សាលាឧទ្ធរណ៍មិនអាចបន្ថែមទោសពីលើមូលទោសបានទេ ។ សាលាឧទ្ធរណ៍អាចជំនួសឈ្មោះបទល្មើសដែលកំណត់ដោយតុលាការជាន់ដំបូងដោយឈ្មោះបទល្មើសមួយទៀតបាន ប៉ុន្តែមិនអាចដាក់ទម្ងន់ទោសលើជនជាប់ចោទបានទេ ។ ប្រសិនបើតុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយដែលដាច់ខាតត្រូវប្រកាសនោះ សាលាឧទ្ធរណ៍ត្រូវបដិសេធសាលក្រមហើយប្រកាសអំពីទោសជាថ្មី ។ ម្យ៉ាងទៀតប្រសិនបើបណ្តឹងនោះបានធ្វើតែជនជាប់ចោទនោះ សាលាឧទ្ធរណ៍មិនអាចបន្ថែមចំនួនទឹកប្រាក់សម្រាប់ជួសជុលការខូចខាតឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីបានទេ [៦៣] ។

## កថាខណ្ឌទី៣ ការបញ្ជូនបណ្តឹងឧទ្ធរណ៍

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ដែលភាគីបានដាក់ពាក្យប្តឹង ក្រឡាបញ្ជីនៃសាលាដំបូងត្រូវរៀបចំសំណុំរឿងបញ្ជូនទៅសាលាឧទ្ធរណ៍ ។ ក្រឡាបញ្ជីត្រូវធ្វើក្នុងរយៈពេលខ្លីបំផុតជូនទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវៈ

- សំណុំរឿងនៃនីតិវិធី

[៦១] មាត្រា ៣៧០ និងមាត្រា ៣៧១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៦២] មាត្រា ៣៩៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[៦៣] មាត្រា ៣៩៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម
- សេចក្តីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម

មុនការបញ្ជូននូវឯកសារទាំងអស់ខាងលើ ក្រឡាបញ្ជីត្រូវធ្វើការសរសេរបញ្ជីរាយនាមលិខិតដែលមាននៅក្នុងសំណុំរឿងជាមុនសិន ។ ក្នុងការធ្វើបញ្ជីរាយនាមលិខិតដោយក្រឡាបញ្ជី គឺមានអត្ថប្រយោជន៍ណាស់ដើម្បីការពារសំណុំរឿងកុំឲ្យមានការបាត់បង់ និងមានភាពងាយស្រួលក្នុងការពិនិត្យ ។ នៅក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការស្តីអំពីការឃុំខ្លួនជនជាប់ចោទ សំណុំរឿងត្រូវបានបញ្ជូនក្នុងរយៈពេល១០ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជំនះបានដែលត្រូវតែបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។ បន្ទាប់មកក្រឡាបញ្ជីនៃសាលាដំបូងត្រូវរក្សារទុកសំណុំរឿងបង្ការទុកនៅកន្លែងដែលសុវត្ថិភាព រួចការងារក្រឡាបញ្ជីត្រូវបានបញ្ចប់នៅពេលដែលបានបញ្ជូន សំណុំរឿងទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងការចុះទៅអនុវត្តជាក់ស្តែងនៅសាលាដំបូងរាជធានីភ្នំពេញទៅលើប្រធានបទខាងលើស្តីពី **"តួនាទីក្រឡាបញ្ជីនៅពេលសវនាការ"** ដែលបានលើកយកមកធ្វើការតាក់តែងបានធ្វើឲ្យយើងខ្ញុំយល់ឃើញថា ក្រឡាបញ្ជីមានតួនាទីយ៉ាងច្រើនទាំងការងារចម្បងៗដែលមានកំណត់នៅក្នុងច្បាប់ និងការងារបន្ទាប់បន្សំផ្សេងៗទៀត ដែលជាហេតុធ្វើឲ្យក្រឡាបញ្ជីមានភាពស្មុគស្មាញយ៉ាងខ្លាំង ។ នៅក្នុងការអនុវត្តការងាររបស់ក្រឡាបញ្ជី មានចំណុចខ្លះច្បាប់បានកំណត់យ៉ាងច្បាស់លាស់នូវតួនាទី ។ ប៉ុន្តែពេលខ្លះតួនាទីរបស់ក្រឡាបញ្ជីមួយចំនួនមិនមានច្បាប់កំណត់ទៅវិញ ដូចជាការទទួលពាក្យបណ្តឹង ការដឹកនាំធ្វើសម្បថ -ល- ។ ទោះបីជាច្បាប់មិនបានកំណត់នូវតួនាទីរបស់ក្រឡាបញ្ជីនេះយ៉ាងណាក៏ដោយក៏ក្រឡាបញ្ជីត្រូវបំពេញតួនាទីនេះ ព្រោះវាជាការងារផ្នែករដ្ឋបាល និងម៉្យាងទៀតដោយសារក្រឡាបញ្ជីជាសេនាធិការរបស់ចៅក្រម ។

បច្ចុប្បន្នយើងឃើញថានៅតាមស្ថាប័នតុលាការនីមួយៗ មានសំណុំរឿងយ៉ាងបានដាក់មកសាលាដំបូង និងអយ្យការអមសាលាដំបូង ដែលទាមទារឲ្យមានក្រឡាបញ្ជីច្រើនជាអ្នកទទួលបន្ទុក។ តែផ្ទុយទៅវិញក្រឡាបញ្ជីនៅមានភាពខ្វះខាតនៅឡើយដែលធ្វើឲ្យមានភាពកកស្ទះនូវសំណុំរឿង និងបានធ្វើឲ្យដំណើរការនៃនីតិវិធីមានភាពយឺតយ៉ាវ ដែលអាចនាំឲ្យប្រជាពលរដ្ឋបាត់បង់នូវទំនុកចិត្តលើតុលាការ ។

ទន្ទឹមនឹងនេះការធ្វើជាក្រឡាបញ្ជីក៏ជួបនូវបញ្ហាខ្លះដែរ ដូចជាមានពាក្យសម្តីមួយចំនួនដែលបានចោទប្រកាន់មកលើក្រឡាបញ្ជីថា កាលណាការសម្រេចសេចក្តីណាមួយដែលមានលក្ខណៈមិនត្រឹមត្រូវ ឬមានដោះលែងជនជាប់ចោទ វាជាកំហុសរបស់ក្រឡាបញ្ជី ព្រោះក្រឡាបញ្ជីគឺជាអ្នកកាន់នៅសំណុំរឿង ឬ គេយល់ថាដោយហេតុក្រឡាបញ្ជីជាអ្នកស៊ីសំណូក ទើបនាំឲ្យការដោះលែងនូវជនជាប់ចោទ ប៉ុន្តែពួកគេមិនបានដឹងទេថាក្រឡាបញ្ជីគ្មានសិទ្ធិក្នុងការសម្រេចសេចក្តីអំពីការដោះលែងជនជាប់ចោទ ឬ លើកលែងចោទចំពោះជនជាប់ចោទនោះទេ ព្រោះសិទ្ធិសម្រេចអ្វីមួយនៅក្នុងសំណុំរឿងគឺជាសមត្ថកិច្ចរបស់ចៅក្រមតែប៉ុណ្ណោះ ។

សរុបសេចក្តីមក ការងាររបស់ក្រឡាបញ្ជីនៅក្នុងវិស័យតុលាការ គឺមានតួនាទីច្រើនដែលទាមទារឲ្យក្រឡាបញ្ជីមានសមត្ថភាពគ្រប់គ្រាន់ និងមានភាពប៉ិនប្រសប់ក្នុងការបំពេញតួនាទីនេះ ។ កាលណាក្រឡាបញ្ជីមានសមត្ថភាព និងមានភាពប៉ិនប្រសប់នេះ ដំណើរការនីតិវិធីគឺមានភាពឆាប់រហ័សដែរ និងពន្លឿននូវនីតិវិធីដែរ ។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និង បានស្វែងយល់ពីតួនាទីរបស់ក្រឡាបញ្ជីរួចហើយ យើងឃើញថាការងារក្រឡាបញ្ជីមាននៅពេលបច្ចុប្បន្ន បានជួបនូវផលវិបាកជាច្រើននូវការងារប្រចាំថ្ងៃដូចជាទី១ ការងាររបស់ក្រឡាបញ្ជីមិនមានកំណត់ច្បាស់លាស់ ទី២ កង្វះខាតក្រឡាបញ្ជី ទី៣ ការងាររៀបចំក្នុងពេលសវនាការ និងទី៤ បញ្ហាប្រាក់បៀវត្ស ។

នៅក្នុងបំពេញតួនាទីក្រឡាបញ្ជី នៅមិនបានការកំណត់ក្នុងច្បាប់ឲ្យបានច្បាស់លាស់នៅឡើយទេ ។ ការអនុវត្តរាល់ថ្ងៃគឺជាការអនុវត្តតាមតៗគ្នា ដែលពេលខ្លះមានការអនុវត្តខុសក៏មាន ។ ដើម្បីឲ្យមានការអនុវត្តត្រឹមត្រូវ រដ្ឋគួរគប្បីបង្កើតនូវច្បាប់ស្ដីលក្ខន្តិកៈក្រឡាបញ្ជីមួយ ដើម្បីឲ្យក្រឡាបញ្ជីដឹងអំពីតួនាទីរបស់ខ្លួនក្នុងការអនុវត្ត ។ ម្យ៉ាងទៀតបច្ចុប្បន្ននេះសំណុំរឿងនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងមានចំនួនច្រើន ចំណែកឯក្រឡាបញ្ជីមានចំនួនតិចនៅឡើយ ដែលធ្វើឲ្យចំណាត់ការសំណុំរឿងមានភាពយឺតយ៉ាវ ហេតុដូចនេះ ទាមទារឲ្យមានការជ្រើសរើសក្រឡាបញ្ជីបន្ថែមទៀត ដើម្បីបំពេញនូវការខ្វះខាតនេះ ។

ក្រៅពីអ្វីដែលបានរៀបរាប់ខាងលើ យើងបានមើលឃើញថាការងាររបស់ក្រឡាបញ្ជីក្នុងការរៀបចំបន្ទប់សាលសវនាការ គឺមានលក្ខណៈមួយដែលបានធ្វើឲ្យមានភាពប៉ះពាល់ដល់កិត្តិយស និងភាពថ្លៃថ្នូររបស់ក្រឡាបញ្ជី ព្រោះថានៅមុនពេលសវនាការក្រឡាបញ្ជីតែងតែមកធ្វើការបើកទ្វារបន្ទប់ រៀបចំសម្ភារៈ ដែលមាននៅក្នុងបន្ទប់ដូចជាធ្វើការជូតតុ ជូតកៅអី រៀបចំតុក្រចកសេះ និងការត្រួតពិនិត្យមើលប្រព័ន្ធឧឃោសនស័ព្ទ ឬប្រព័ន្ធអគ្គិសនីផ្សេងទៀត ដែលជាចំណុចគួរឲ្យលុបបំបាត់ ហើយសាលាដំបូងនីមួយៗគប្បីមានមន្ត្រីម្នាក់ទទួលបន្ទុកក្នុងការរៀបចំសាលសវនាការនេះ ។

ក្រៅពីនេះការងារក្រឡាបញ្ជីសវនាការដែលបានកោះហៅទៅភាគីពាក់ព័ន្ធ ដោយបានបញ្ជូនដីកាតាមរយៈមន្ត្រីទទួលបន្ទុកក្នុងការបញ្ជូន គឺមានភាពពិបាកណាស់ដោយហេតុថា ពេលបញ្ជូនដីកាម្ដងៗ ការបង្វិលចុងដីកាមកវិញគឺមានភាពយឺតបំផុត ហើយពេលខ្លះគ្មាននឹងបង្វិលចុងដីកាមកវិញទៀត ដែលជាហេតុធ្វើឲ្យដំណើរការនីតិវិធីក្នុងពេលសវនាការជួបនូវបញ្ហាក្នុងការកំណត់ថានូវសាលក្រមណា ជាសាលក្រមចំពោះមុខ ឬជាសាលក្រមកំបាំងមុខនោះទេ ។ ដូច្នេះនៅតាមតុលាការគួររៀបចំកន្លែងណាមួយសម្រាប់ផ្ទុកនូវចុងដីកាត្រឡប់មកវិញ ។ លើសពីនេះ ការបញ្ជូនដីកាតាមរយៈប្រៃសនីយ៍ រដ្ឋគួបង្កើតច្បាប់ស្ដីពីការគ្រប់គ្រង់ប្រៃសនីយ៍ ដើម្បីងាយស្រួលក្នុងការបញ្ជូនដីកា ឬលិខិតផ្សេងៗ ព្រោះការបញ្ជូនដីកាតាមរយៈប្រៃសនីយ៍ គឺមិនដែលឃើញមានចុងដីកាបង្វិលពីប្រៃសនីយ៍មកតុលាការវិញនោះឡើយ ។

បន្ថែមពីនេះទៅទៀត បើយើងក្រឡេកមើលទៅលើប្រាក់បៀវត្សរបស់ក្រឡាបញ្ជីវិញ មានលក្ខណៈតិចតួចណាស់ បើធៀបជាមួយជាមួយចៅក្រម និងព្រះរាជអាជ្ញា ។ ដោយសារតែប្រាក់បៀវត្សនៅមានភាពតិចតួច បច្ចុប្បន្ននេះមានក្រឡាបញ្ជីខ្លះបានផ្លាស់ប្តូរនូវតួនាទីរបសខ្លួនពីការងារជាក្រឡាបញ្ជី ទៅបម្រើការងារជាមេធាវី ឬជាចៅក្រម ឬព្រះរាជអាជ្ញា ឬក្រឡាបញ្ជីមួយចំនួនទៀតបានយកពេលវេលាប្រើការងារ ទៅធ្វើការរកស៊ីបន្ថែម ព្រោះពួកគេយល់ថា ការងារជាមេធាវី ឬជាចៅក្រម ឬព្រះរាជអាជ្ញាអាចធ្វើឲ្យជីវភាពគ្រួសារមានភាពធូធារ ។ ដូច្នេះរដ្ឋាភិបាល គួរគិតគូរដំឡើងប្រាក់បៀវត្សរបស់ក្រឡាបញ្ជីឲ្យមានសមល្មម ដែលអាចអោយក្រឡាបញ្ជីមានជីវភាពធូធារ ។

## ឯកសារយោង

១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២.ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

៣.សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈដោយឡែករបស់ក្រឡាបញ្ជី

៤.អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិកាដ្ឋាន

៥.អនុក្រឹត្យស្តីពីមន្ត្រីទទួលបន្ទុកអាជ្ញាសាលា

៦.មេរៀនតួនាទីក្រឡាបញ្ជីសវនាការរបស់លោក អឿន សៀង ចៅក្រមតុលាការកំពូល

៧.របាយការណ៍ស្តីពីតួនាទីក្រឡាបញ្ជីក្នុងការកោះហៅសាក្សីរបស់លោក យ៉ាត ថារី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ និងជាអតីតសិស្សក្រឡាបញ្ជីជំនាន់ទី៣

៨.ឯកសាររបស់សាលាដំបូងរាជធានីភ្នំពេញ(សាលក្រម ដីកាកោះ ដីកាបញ្ជូន..................)

# ឧបសម្ព័ន្ធ